ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សហគ្រាសសង្គម និងកុមារ




## បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
## គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក WORLD EDUCATION

Child Social & Financial Education

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៧០១៧ **អយក.**ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅ " សហគ្រាសសង្គម និងកុមារ "

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៨៤អនក្របក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ២០០៥-២០០៩
- យោងសេចក្តីណែនាំលេខ០៣ អយក. សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២
- យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេសនាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

**សម្រេច**

ប្រការ១- អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ" សហគ្រាសសង្គមនិងកុមារ " ដែលជាស្នាដៃនិពន្ធនិងរៀបរៀងរបស់អង្គការអប់រំពិភពលោកសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀន និងរៀនកម្មវិធីបំណិនជីវិតនៅតាមអនុវិទ្យាល័យ ។

ប្រការ២ - អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការអប់រំពិភពលោក ត្រូវអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១៤

**បណ្ឌិត ហង់ ជួន ណារ៉ុន**

កន្លែងទទួល :
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- កាលប្បវត្តិ- ឯកសារនា.អកស.

អាគារលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១០ ១៤៣ /២១៧ ២៥៣ /៨១៦ ៤៩១ ទូរសារ (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh   គេហទំព័រ : www.moeys.gov.kh

**គណៈកម្មការអភិវឌ្ឍសៀវភៅ**
**"សហគ្រាសសង្គម និង កុមារ"**

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោក អេង សុខ
២. លោក វីលៀម វ៉ាន់ឌឺវ៉ាល់

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណឆន
២. លោក ប៊ុត សុភាន់
៣. លោក ផុក ចាន់ថុល

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ(USAID)

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា........................................ ក

វត្ថុបំណងរួម........................................ ខ

ការត្រៀមលក្ខណៈមុនពេលបង្រៀន........................................ ខ

ខ្លឹមសារសង្ខេប........................................ គ

មេរៀនទី ១៖ ការរៀបចំគម្រោង ........................................ ១

មេរៀនទី ២៖ ជំនួញធំ........................................ ៩

មេរៀនទី ៣៖ ការងារសកល........................................ ១៤

មេរៀនទី ៤៖ ការលេងកំសាន្ត........................................ ១៩

មេរៀនទី ៥៖ កន្លែងរបស់ខ្ញុំ ........................................ ២៤

មេរៀនទី ៦៖ គួរធ្វើ និង មិនគួរធ្វើ........................................ ២៧

មេរៀនទី ៧៖ ការសម្រេចចិត្ត........................................ ៣២

មេរៀនទី ៨៖ ការងារ និងឧបករណ៍........................................ ៣៧

មេរៀនទី ៩៖ ការកំណត់........................................ ៤៣

មេរៀនទី ១០៖ ការបញ្ចប់........................................ ៤៧

# អារម្ភកថា

វិស័យអប់រំជាវិស័យមួយ រួមចំណែកសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការអភិវឌ្ឍធនធានមនុស្ស។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍលើគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់ បណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងមានជំនាញជាក់លាក់ ដើម្បីបំពេញលើគ្រប់លក្ខខណ្ឌការងារ។

ឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរីរបស់សង្គមជាតិ ក្រសួងអប់រំ យុវជននិងកីឡា បានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សា និងគោលនយោបាយអប់រំបំណិនជីវិត សម្រាប់អនុវត្តន៍នៅតាមសាលារៀនចំណេះទូទៅ។

កម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ ដែលផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋាន និងពង្រឹងជំនាញផ្សេងៗ ដែលមានសារៈសំខាន់សម្រាប់ស្រូបយកបទពិសោធន៍ល្អៗ ក្នុងការពង្រឹងចំណេះដឹង និងបំណិនចាំបាច់ដើម្បីបម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

ចរិតលក្ខណៈមួយ ក្នុងចំណោមចរិតលក្ខណៈជាច្រើនរបស់សង្គមកម្ពុជាគឺជាការកើនឡើងដ៏ខ្ពស់នៃ អត្រាតម្លៃនៅតាមហាងតូចៗ និងបណ្តាសហគ្រាសជាច្រើនទៀត។ ភាពជាសហគ្រិនគឺជាអ្វីដែលមាន មូលដ្ឋានដ៏រឹងមាំមួយ។វាពិតជាសេចក្តីត្រូវការមួយ ដើម្បីផ្តល់ឱ្យយុវជននូវបំណិនជីវិតដែលពោរពេញទៅដោយភាពជាសហគ្រិន ដូច្នេះពួកគេ ប្រាកដជាអាចមានលទ្ធភាពដើម្បីធ្វើការអភិវឌ្ឍបានយ៉ាងជោគជ័យទៅលើជម្រើសនៃមុខរបរសេដ្ឋកិច្ច។ ក្រៅពីការប្រមើលមើលជាវិជ្ជមាន និងការជឿជាក់ទៅលើខ្លួនឯង វាក៏នឹងជួយឱ្យប្រជាជនវ័យក្មេងត្រៀមខ្លួនដោះស្រាយភាពមិនច្បាស់លាស់ទាំងឡាយនៃជិវិត។ ចំពោះចរិតលក្ខណៈដទៃទៀត គឺជារបៀបដែលសហគមន៍ទាំងឡាយបានរៀបចំ។

មានចំណងទាក់ទងដ៏រឹងមាំមួយ ជាមួយនឹងសមាជិកដទៃទៀតរបស់ភូមិ ហើយរឿងរ៉ាវផ្សេងៗ ទៀតក៏ត្រូវបានចែករំលែកផងដែរ។ ដោយសារតែសាលារៀនអាចចូលរួមបានយ៉ាងធំធេងចំពោះទិដ្ឋភាពសង្គមមួយនេះ ដូច្នេះហើយទើបមានសារៈសំខាន់ណាស់ ក្នុងការស្វែងរកនូវមធ្យោបាយដទៃៗទៀតដើម្បីធ្វើការជាមួយ និងជាមួយសហគមន៍ផងដែរ។ ចំណេះដឹងអំពីសង្គម និងការរីកចំរើនផ្នែក គុណភាពជីវិត គឺជាពាក្យដែលធ្ងន់ធ្ងរណាស់ ក៏ប៉ុន្តែវាក៏ត្រូវបានស្វែងរកតាមវិធីធូរស្រាល និង កំសាន្ត។ នេះគឺជាអ្វីដែលម៉ូឌុលនេះប៉ងចង់ធ្វើ។

សិស្សទាំងឡាយនឹងបង្កើតសហគ្រាសតូចមួយ ដោយប្រើប្រាស់នូវការជំរុញមួយជំហានៗ ហើយ និងការរៀបចំឱ្យបានល្អដោយបង្កើតគម្រោងជំនួញមួយ។ ពួកគេនឹង កំណត់គោលដៅមួយចំនួន ហើយបង្កើតតារាងពេលវេលាមួយ។ គោលបំណងទីមួយ គឺត្រូវតែធ្វើការ ជាមួយគ្នា ហើយជួយគ្នាទៅវិញទៅមក ក្នុង គោលបំណងដើម្បីបង្កើននូវលទ្ធផល។

នៅពេលដែលគោលបំណងនេះត្រូវបានឈានដល់គោលដៅ សិស្សទាំងឡាយនឹងប្រើប្រាស់ចំណេះដឹងរបស់ពួកគេ ហើយក៏អាចរកបាននូវប្រាក់កម្រៃ ដើម្បីរៀបចំនូវព្រឹត្តិការណ៍មួយសម្រាប់ (ផ្នែកមួយនៃ) សហគមន៍។ នេះនឹងក្លាយជាការដាស់តឿន ឬក៏លើកទឹកចិត្តដោយផ្តល់ចំណេះដឹងអំពីសង្គមរបស់ពួកគេផងដែរ ហើយក៏អាចធ្វើឱ្យពួកគេទទួលបាននូវបទពិសោធន៍ស្តីអំពីសារៈសំខាន់ និងភាពល្អប្រសើរយ៉ាងណា ដើម្បីក្លាយជាសមាជិក សង្គមដ៏សកម្ម និងពោរពេញដោយគំនិតថ្មី។

## ១. វត្ថុបំណងរួម

ក្នុងបំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈដែលអាចជួយដល់ការសម្រេចចិត្តក្នុងការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព អាចដោះស្រាយបាន គ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួម ចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវភាពប្រកបដោយផលិតភាព។ *(គោលនយោបាយបំណិនជីវិត ២០០៦)* ។ ក្រោយពេលរៀនចប់សិស្សទាំងអស់មានសមត្ថភាពៈ

- គិតស៊ីជម្រៅទាក់ទងគ្នាជាមួយនឹងប្រធានបទសង្គមដូចជាការងារ ពេលទំនេរ ហើយនិងពលកម្មកុមារ។
- វិភាគទៅលើការរួមចំណែកផ្ទាល់របស់ពួកគេ និងការខិតខំប្រឹងប្រែងទាំងឡាយរបស់អ្នកដទៃដើម្បីឈានទៅដល់គោលដៅរួមរបស់ពួកគេ
- ដោះស្រាយបញ្ហា និងការស្វែងរកនូវជម្រើសផ្សេងៗ នៅពេលដែលប្រឈមមុខជាមួយនឹង ការរំពឹងទុកទាំងឡាយណាដែលមិនមានលក្ខណៈពិតប្រាកដ
- ចែករំលែកចំណេះដឹង បទពិសោធន៍ និងការអភិវឌ្ឍទៅលើកំណែទម្រង់យុទ្ធសាស្ត្រថ្មីជាមួយនឹងបញ្ហាទាំងអស់នោះ
- អភិវឌ្ឍភាពជាអ្នកដឹកនាំ និង ការផ្តួចផ្តើមគំនិត
- ផ្តល់កំលាំងចិត្តទៅលើភាពទទួលខុសត្រូវ និងទៅលើបញ្ហាផ្សេងៗទៀត។

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ឯកសារនេះចែកចេញជា ១០ផ្នែក ហើយមានវត្ថុបំណងខុសៗគ្នា។ ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្សជាដំណាក់កាលត្រៀមរបស់គ្រូ។ ព័ត៌មានទាក់ទងនឹងការបង្រៀន និងរៀន ពិសេសមេរៀន ត្រូវបានគ្រូត្រៀមទុកជាមុនក្នុងកិច្ចតែងការបង្រៀន។

**● សម្ភារឧបទេស**

ភាគច្រើនសម្ភារៈទាំងអស់នោះ គឺជា សម្ភារមូល ដ្ឋានដែលមានដូចជាប៊ិច ឬក្រដាស។ សម្ភារៈដទៃៗទៀតដែលមាននៅក្នុងមេរៀន នឹងត្រូវបានផ្តល់ជូនតាមរយៈឯកសារសម្រាប់សិស្ស ដែលត្រូវបានភ្ជាប់មកជាមួយនៅក្នុងឯកសារនេះ។

**● វត្ថុបំណង**

ផ្តល់នូវឃ្លាបញ្ជាក់ពីអ្វីនឹងត្រូវសម្រេចបាន និងវាយតម្លៃនៅខាងចុងមេរៀន។ ឃ្លាទាំងនេះទាក់ទងនឹងគោលដៅរួមរបស់បំណិនជីវិត ដែលបានកំណត់នៅក្នុងគោលការណែនាំបំណិនជីវិតនៅមធ្យមសិក្សាបឋមភូមិ ព្រមទាំងកំណត់នៅក្នុងបំណិនទាក់ទងសង្គមតាមមូលដ្ឋាន បំណិនអាជីវកម្ម សេដ្ឋកិច្ច និងការងារ និងបំណិន អាជីពងាយៗ។

**● សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ**

ខាងក្រោមនេះ ជាសញ្ញាសម្គាល់សកម្មភាពងាយៗដើម្បីឱ្យគ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀន និងរៀន។

 ធ្វើសកម្មភាព ៖ គ្រូត្រូវធ្វើសកម្មភាពផ្ទាល់ខ្លួន

 សរសេរ ៖ អ្វីមួយដែលចាំបាច់ត្រូវធ្វើការសរសេរ ដែលភាគច្រើនគឺសរសេរនៅលើក្តារខៀន

 សួរសំណួរ ៖ មានសំណួរសំខាន់ៗមួយចំនួន ដែលអាចត្រូវសួរទៅកាន់សិស្ស

 ពន្យល់ ៖ ពន្យល់ ឬ ក៏ប្រាប់នូវព័ត៌មានសំខាន់ៗទៅកាន់សិស្សនៅក្នុងថ្នាក់ ។

● **លំនាំបង្រៀន**

មេរៀននីមួយៗចែកជា ៣ផ្នែក។ ផ្នែកទី១ គឺជាសេចក្តីផ្តើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅនឹងចំណេះដឹងដែលសិស្សមានស្រាប់ ឬរំលឹកទៅមេរៀនចាស់។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗដោយផ្អែកលើវិធីសាស្ត្រ បង្រៀនបែបការងារគម្រោង(ចុះស្រាវជ្រាវ ប្រមូលព័ត៌មាន សម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...។) និងយុទ្ធវិធីបង្រៀនផ្សេងៗទៀត។ នៅផ្នែកទី៣ ដែលជាផ្នែកបញ្ចប់ យើងអាចធានាបានថា រាល់លទ្ធផលនៃការសិក្សារបស់យើងគឺបានឆ្លងកាត់នូវយុទ្ធវិធីខុសៗគ្នាជាច្រើន។

## ៣. ខ្លឹមសារសង្ខេប

ខ្លឹមសារសង្ខេបផ្តល់ឱ្យគ្រូ ដើម្បីជាទុនខ្លះក្នុងការបង្រៀនហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារៈសំខាន់រវាងមេរៀននីមួយៗ ។

ខាងក្រោមនេះ គឺជាខ្លឹមសារសង្ខេបរួមទាំង ១០ មេរៀនដែលនៅក្នុងឯកសារបំណិនជីវិតនេះ ៖

| ចំណងជើងមេរៀន | រយៈពេល | ខ្លឹមសារ | ទំព័រ |
|---|---|---|---|
| ១. ការរៀបចំគម្រោង | ១ម៉ោង ៣០នាទី | យើងទាំងអស់គ្នាគិតអំពីកិច្ចការដ៏ល្អមួយ ។ តើយើងត្រូវធ្វើការជាមួយគ្នាដោយរបៀបណា?បន្ទាប់ពីនេះ យើងចែករំលែកនូវបទពិសោធន៍ទាំងឡាយស្តីអំពីសហគ្រាសតូចៗហើយយើង នឹងបំផុសនូវគំនិតថ្មីឡើង ស្តីអំពីមធ្យោបាយផ្សេងៗក្នុងការរកប្រាក់កម្រៃ។ | ១ |
| ២. ជំនួញធំ | ១ម៉ោង ៣០នាទី | យើងគិតគូរបន្ថែមអំពីកិច្ចការទាំងឡាយដែលមកជា មួយនឹងគម្រោងរបស់យើង។សិស្សគ្រប់គ្នានឹងធ្វើការជ្រើសរើស កិច្ចការមួយចំនួន ដែលសមស្របជាមួយនឹងបទពិសោធន៍ និងចំណាប់អារម្មណ៍របស់ពួកគេ។ គម្រោងនៃ ការធ្វើជំនួញមួយក៏នឹង ត្រូវបានបង្កើតឡើងផងដែរ។ | ៩ |
| ៣.ការងារសកល | ១ម៉ោង ៣០នាទី | សិស្សានុសិស្សទាំងឡាយគិតគូរអំពីផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមាននៃការចាប់ផ្តើមធ្វើការនៅវ័យក្មេង។ ពួកគេត្រូវសិក្សាទៅលើតុល្យភាពរវាងការងារ និងពេលសម្រាក។ | ១៤ |
| ៤. ការលេងកំសាន្ត | ១ម៉ោង ៣០នាទី | នៅក្នុងមេរៀននេះ យើងត្រិះរិះរកគំនិតថ្មីស្តីអំពី សារសំខាន់នៃការលេង ហើយយើងក៏បង្កើតនូវសំណួរ ដើម្បីអង្កេតទៅលើតម្រូវការ សម្រាប់ការធ្វើឱ្យប្រសើរឡើង ផ្នែកកម្សាន្តសប្បាយ។ | ១៩ |
| ៥. កន្លែងរបស់ខ្ញុំ | ១ម៉ោង ៣០នាទី | សិស្សទាំងឡាយធ្វើទស្សនកិច្ចសិក្សាទៅកាន់សហគមន៍មួយ ដើម្បីរៀបចំការស្រាវជ្រាវរបស់ពួកគេស្តីអំពីការលេងកម្សាន្ត ហើយពួកគេចែករំលែកផងដែរនូវបទពិសោធន៍ របស់ពួកគេ។ | ២៤ |

| | | | |
|---|---|---|---|
| ៦. គួរធ្វើ និងមិនគួរធ្វើ | ១ម៉ោង ៣០នាទី | រាល់ក្រុមដែលធ្វើការស្ទង់មើល ត្រូវវិភាគនូវលទ្ធផលរបស់ពួកគេ ក៏ដូចរកមើលនូវភាពដូចគ្នា និងខុសគ្នា។ ពួកគេក៏ត្រូវគិតផងដែរ អំពីការដោះស្រាយបញ្ហា និងវិធីក្នុងការធ្វើបទបង្ហាញពីគំនិតរបស់ពួកគេទៅកាន់មិត្តរួមថ្នាក់ទាំងឡាយ។ | ២៧ |
| ៧. ការសម្រេចចិត្ត | ១ម៉ោង ៣០នាទី | ដោយពឹងផ្អែកទៅលើចំនួនលុយដែលរកបាន យើងធ្វើការសម្រេចចិត្ត ថាតើប្រភេទព្រឹត្តិការណ៍អ្វីដែលយើងអាចធ្វើការរៀបចំសម្រាប់សហគមន៍។ | ៣២ |
| ៨. ការងារ និង ឧបករណ៍ | ១ម៉ោង ៣០នាទី | សិស្សបង្កើតគម្រោងមួយដើម្បីបែងចែកការងារទាំងឡាយ និងគិតអំពីជំហានចាំបាច់ក៏ដូចជាសម្ភារៈទាំងឡាយ។ ដូច្នេះពួកគេ ត្រូវតែមានគំនិតឆ្ពោះទៅមុខ ហើយបង្កើតជាកិច្ចព្រមព្រៀងទាំងឡាយណាដែលមានលក្ខណៈសាមញ្ញ។ | ៣៧ |
| ៩. ការកំណត់ | ១ម៉ោង ៣០នាទី | បន្ទាប់ពីត្រួតពិនិត្យចុងក្រោយរួច សិស្សទាំងអស់គ្នាហាត់សមសំដែងនៅអំឡុងពេលព្រឹត្តិការណ៍នោះផងដែរ។យើងឯកភាពគ្នាឡើងវិញ ហើយផ្តោតទៅលើសារៈសំខាន់នៃការជួយគ្នាទៅវិញទៅមក និងភាពក្លាយទៅជាសមាជិកសកម្មមួយរូបនៃក្រុមរបស់យើង។ | ៤៣ |
| ១០. ការបញ្ចប់ | ១ម៉ោង ៣០នាទី | អបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ និងការទទួលបានជោគជ័យចំពោះការរៀបចំឡើងនូវព្រឹត្តិការណ៍មួយនេះ។ ពួកគេអាចជួយបង្គ្រប់បន្ថែមឱ្យគ្នាទៅវិញទៅមកហើយក៏ផ្តល់នូវមតិរិះគន់ជាវិជ្ជមានផងដែរ ចំពោះការរួមចំណែកដែលបានមកពីរាល់សមាជិកក្រុមទាំងអស់។ នៅចុងបញ្ចប់ ពួកគេគិតអំពីមធ្យោបាយដែលមានការច្នៃប្រឌិត ដើម្បីបង្ហាញនូវអ្វីដែលពួកគេចូលចិត្តក្នុងគម្រោងនេះ។ | ៤៧ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន ២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរ ដែលយើងត្រូវបញ្ចូលនៅផ្នែកខាងចុងឯកសារ ។ ផ្នែកមួយទៀត ជាការវាយតម្លៃទៅលើឥរិយាបថសិស្ស ដោយគ្រូជាអ្នកសង្កេតផ្ទាល់រៀងរាល់ថ្ងៃ ហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ ។ ចំពោះការវាយតម្លៃសិស្ស យើងគិតពិន្ទុ ៥០ស្មើទៅនឹងមុខវិជ្ជាមួយចំនួន ផងដែរ គឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

នៅតាមមេរៀននីមួយៗ គ្រូទុកពេលឱ្យសិស្សពិភាក្សាក្រុមតូចឱ្យបានច្រើន នៃចំណុចសំខាន់ៗនៅពាក់កណ្តាលមេរៀននីមួយៗ។ កំឡុងពេលសិស្សពិភាក្សាក្រុមតូច ជាពេលវេលាដែលគ្រូអាចសង្កេតឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។ ជាការល្អគ្រូគួរដាក់ពិន្ទុឥរិយាបងសិស្សចាប់ពីមេរៀនទី ៦ តទៅ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះផ្តល់នូវព័ត៌មានរួមសម្រាប់គ្រូប្រើប្រាស់ រួមទាំងផ្ទាំងរូបភាពសម្រាប់គ្រូប្រើប្រាស់នៅក្នុងមេរៀននេះ។

# មេរៀនទី ១: ការរៀបចំគម្រោង

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាស
- ថតចម្លងសន្លឹកកិច្ចការ១.១ (មួយច្បាប់សម្រាប់សិស្ស៤នាក់ )
- ល្បែងកំសាន្ត "ជំនួញមិនល្អ" ។

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- វិភាគលទ្ធផលវិជ្ជមាន និងអវិជ្ជមានដែលទទួលបានពីបទពិសោធន៍មុនៗរបស់សិស្សផ្សេងទៀត
- ពន្យល់ពីសារៈសំខាន់នៅពេលធ្វើការងារជាក្រុម
- ចូលរួមធ្វើការងារជាមួយគ្នាទៅលើការពិភាក្សាអំពីច្បាប់ជាមូលដ្ឋាន
- ផ្តល់នូវគំនិតដែលប្រកបដោយប្រឌិតញាណយ៉ាងហោចណាស់ឱ្យបានមួយដែលស្តីអំពីវិធីក្នុងការរកប្រាក់កម្រៃនៅក្នុងសហគមន៍របស់ពួកគេ។

**ចំណងជើងមេរៀន ៖ ការរៀបចំគម្រោង** 🕑 ១០ នាទី

**សេចក្តីផ្តើម**

ចូរឈរជារង្វង់ធំមួយ។

អ្នកស្ម័គ្រចិត្តមួយរូបដើម្បីបិទភ្នែករបស់អ្នកចូលរួមលេងល្បែង ២ ឬ ៣ នាក់ ហើយបន្ទាប់មកជ្រើសរើសឱ្យពួកគេដើរឆ្លងកាត់រង្វង់មូល។នៅពេលដែលពួកគេធ្វើដំណើរដល់ផ្នែកម្ខាងទៀតអ្នកដែលឈរពួកគេជាងគេជាអ្នកបញ្ជប់ពួកគេដោយ*ថ្នមៗ* ហើយធ្វើការចាប់ បង្វិលពួកគេជុំវិញខ្លួនឯង រួចដើរទៅទីតាំងផ្សេងទៀត។

បន្ទាប់មក សុំអ្នកស្ម័គ្រចិត្តម្នាក់ផ្សេងទៀតលេងល្បែងនេះបន្ត និងស្នើសុំអ្នកចូលរួមទាំងអស់ផ្តល់មតិរិះគន់។ បន្ទាប់មកទៀត ប្រមូលផ្តុំគ្នាជាក្រុមឈរនៅជុំវិញក្តារខៀនដែលមានក្រដាសសមួយសន្លឹកបិទនៅលើវា។

ចូរសន្ទនាជាលក្ខណៈអប់រំមួយ ជាមួយនឹងសិស្សានុសិស្ស។ សាកសួរអំពីអ្វីដែលមានសារៈសំខាន់នៅពេល

ធ្វើការងារជាមួយគ្នា។ អនុញ្ញាតឱ្យសិស្សបញ្ចេញយោបល់ចំពោះប្រធានបទដែលត្រូវបានលើកឡើងដោយសិស្សដទៃ។

នៅក្នុងមេរៀនបន្ទាប់ អ្នកនឹងធ្វើការជាក្រុម ដូច្នេះវានឹងមានសារៈសំខាន់ក្នុងការយល់ព្រមទៅលើគន្លឹះនៃការធ្វើការជាមួយគ្នាទាំងនេះ។ តើអ្នកទាំងអស់គ្នាយល់ស្របឬទេ?

ចូរផ្ដល់នូវកន្លែងអង្គុយណាដែលអាចមើលឃើញ នៅក្នុងថ្នាក់




**សកម្មភាពទី២ ៖ ការបង្កើតជំនួញ** ◷ ៦០ នាទី

ចូរប្រមូលផ្ដុំសិស្សទាំងអស់គ្នាឱ្យនៅជុំវិញគុ។ សម្រាប់ទំនាក់ទំនងល្អ យើងគួររៀបចំតែដាក់កៅអី និងតុជារាងអក្សរ U។

ឯកសារនេះ យើងនឹងរៀបចំជាសកម្មភាពសប្បាយមួយ សម្រាប់សហគមន៍របស់យើង។ ប៉ុន្តែការពិតយើងនឹងត្រូវរកប្រាក់កម្រៃមួយចំនួន ដើម្បីចំណាយទៅលើរបស់មួយចំនួនដែល យើងត្រូវការ។ យើងនឹងអាចរកប្រាក់បានដោយការធ្វើការងារ។ យើងគ្រាន់តែដឹងនូវ*អ្វីដែល ត្រូវរៀបចំនៅពេលដែលយើងអាចប៉ាន់ប្រមាណថាលុយចំនួនប៉ុន្មានដែលយើងមាន។*

✋ ឱ្យសិស្សទាំងអស់អង្គុយជាមួយគ្នា ហើយធ្វើការងារនៅក្នុងក្រុមដែលមានគ្នា ៤នាក់ *ព្រមជាមួយ នឹងឯកសារ ១.១ សម្រាប់សិស្ស។* រយៈពេល១៥នាទីក្រោយមក ធ្វើការប្រមូលក្រុមសាជាថ្មីម្ដងទៀត ដោយស្ថិតនៅជុំវិញគុ។

◈ ចូរធ្វើការសួរសំណួរមួយចំនួន ដើម្បីឱ្យសិស្សចែករំលែកចម្លើយរបស់ពួកគេ ពី*ឯកសារ ១.១ ចែកសិស្ស*

- តើក្រុមណាមួយមានដំបូន្មានល្អៗ សម្រាប់ក្រុមដទៃស្ដីអំពីការចាប់ផ្ដើមបង្កើតសហគ្រាសមួយ?
- តើកំហុសណាមួយដែលអ្នកបង្កើតឱ្យមាននៅពេលដែលចាប់ផ្ដើម បង្កើតសហគ្រាសមួយ?

✎ ចូរធ្វើការផ្ដុំនូវកំហុសដែលអាចកើតមានឡើងនៅក្នុងបញ្ជីមួយ ឱ្យសិស្សសរសេរនូវកំហុសទាំងអស់នោះនៅក្នុងក្រដាសទទេមួយ ។ ទុកចំណុចនេះសម្រាប់ធ្វើការសិក្សានៅមេរៀនបន្ទាប់។

ការបង្កើតជំនួញ ៖ ដើម្បីបង្កើតនូវសកម្មភាពសប្បាយមួយ យើងត្រូវរកលុយមួយចំនួនសិន។ សិស្សទាំងអស់គ្នានឹងត្រូវបង្កើតគម្រោងមួយ ដើម្បីធ្វើការបង្កើតជាជំនួញមួយជាមួយនឹងក្រុមរបស់យើង ។ ដំបូងយើងត្រូវតែគិតអំពីប្រភេទការងារ ឬសហគ្រាសអ្វីដែលយើងនឹងបង្កើតតាមរយៈសំណួរ តើវាពិតជាសំខាន់ដែរឬទេ ដែលរាល់ក្រុមនីមួយៗមិនធ្វើអ្វីដែលដូចគ្នា?ចូរយកចិត្តទុកដាក់ចំពោះ *ការបង្កើតនូវគំនិតតែមួយ។* នៅពេលដែលអ្នក គឺជាអ្នកលក់ការ៉េមនៅលំដាប់លេខរៀងទី១០ អ្នកប្រហែលជាលក់បានការ៉េមតិចជាងអ្នកលក់ការ៉េម ដែលមានតែម្នាក់ឯង។

ចែកឯកសារ ១.២ សម្រាប់សិស្ស។ សិស្សទាំងអស់គ្នាអាចធ្វើការជាមួយនឹងឯកសារទាំងអស់នោះបាន។ បន្ទាប់ពីបានបញ្ចប់នូវការ*អង្កេតមើល* តំណាងក្រុមនីមួយៗគឺត្រូវបានអញ្ជើញឱ្យមកធ្វើការ ពន្យល់នូវគំនិតរបស់ពួកគេទៅវិញទៅមក។

អ្នកអាចធ្វើដូច្នេះបានដោយការផ្លាស់ប្តូរគ្នាធ្វើទៅវិញទៅមក។ ចូរឱ្យសមាជិកនៃក្រុមនីមួយៗនូវលេខចំនួនមួយព្រមទាំងនិយាយប្រាប់ថា *រាល់អ្នកបានលេខ១ អង្គុយនៅទីនេះ រាល់អ្នកបានលេខ២អង្គុយនៅទីនោះ។ល។ និងធ្វើការលាយនូវក្រុមទាំងអស់ចូលគ្នា។* គ្រប់ៗគ្នាមានរយៈពេល ៣០វិនាទី ដើម្បីធ្វើការពន្យល់នូវគំនិតរបស់ពួកគេនៅក្នុងក្រុម រយៈពេល៣០វិនាទី ខ្ញុំនឹងប្រាប់នៅពេលដែលក្រោយមក។ បន្ទាប់ពីនោះមកអ្នកផ្សេងទៀតមានរយៈ ពេល ១នាទី ដើម្បីធ្វើការសរសេរចូលនូវការអត្ថាធិប្បាយ និងការទូន្មានទាំងឡាយដែលមានស្តីអំពីគំនិតនេះ។ ចូរធ្វើការឆ្លាស់វេនគ្នាទៅមកៗ រហូតដល់អ្នកគ្រប់គ្នាបានប្រាប់អំពីគំនិតរបស់ខ្លួន និងយក នូវការអត្ថាធិប្បាយ ក៏ដូចជាការទូន្មានទាំងអស់នោះត្រលប់ទៅកាន់ក្រុមរបស់អ្នក។ នៅក្នុងក្រុមរបស់ខ្លួនឯង សិស្សទាំងអស់គ្នាត្រូវផ្តល់អាទិភាពទៅលើមតិរិះគន់របស់ខ្លួន។ យើងត្រូវតែបង្កើតជាបញ្ជី មួយសម្រាបសរសេរឈ្មោះគួរធ្វើចំនួន ៥ និងឈ្មោះមិនគួរធ្វើចំនួន៥ ដែលសុទ្ធតែជាប់ទាក់ទងទៅនឹងជំនួញរបស់យើង។ នៅពេលដែលបានធ្វើរួចហើយ យើងអាចចាប់ផ្តើមធ្វើការងារទៅលើផែនការដ៏ពិតប្រាកដព្រោះយើងបានរៀបចំយ៉ាងល្អ។ ទាំងអស់នេះនឹងត្រូវបញ្ចប់នៅមេរៀនក្រោយ។ អនុញ្ញាតឱ្យសិស្ស គិតអំពីសកម្មភាពទាំងឡាយដែលបានធ្វើនៅក្នុងមេរៀននេះ។

◈ សួរសំណួរ៖ "សព្វថ្ងៃនេះតើអ្នកបានធ្វើអ្វីខ្លះ?" "តើអ្នកបានរៀនអ្វីខ្លះ?" ឬ "តើអ្នកចូលចិត្តអ្វីខ្លះ?"
សិស្សានុសិស្សទាំងឡាយត្រូវតែត្រលប់ទៅកន្លែងរបស់ខ្លួនវិញ។

**សកម្មភាពទី ៣: ល្បែង "ជំនួញមិនល្អ"** ⌚ ២០ នាទី

សិស្សគ្រប់ៗគ្នានឹងត្រូវជ្រើសរើសយក ប័ណ្ណមួយសន្លឹកចេញពីល្បែងនេះ។ កញ្ចប់មួយ គឺសម្រាប់សហគ្រិន រីឯកញ្ចប់មួយទៀត គឺសម្រាប់អតិថិជន។ សិស្សទាំងអស់គ្នាត្រូវតែធ្វើការច្នៃប្រឌិត ដោយពឹងផ្អែកទៅលើព័ត៌មានដែលមាននៅលើប័ណ្ណនីមួយៗ។

ឧទាហរណ៍៖ អ្នកលក់ការ៉េមម្នាក់ កំពុងប្រឈមមុខជាមួយនឹងបុគ្គលផ្សេងម្នាក់ទៀតដែលមិនមានលុយ ក៏ប៉ុន្តែ បុគ្គលម្នាក់នោះ កំពុងព្យាយាមទិញការ៉េមដោយឥតមានលុយសោះ។ តើអ្នកមានប្រតិកម្មដូចម្តេចដែរ?



សិស្សទាំងអស់គ្នា គឺត្រូវបានលើកទឹកចិត្តឱ្យមើលនិងផ្តល់នូវគំនិតផ្សេងៗចំពោះប្រតិកម្មនេះ។ វាពិត ជាមានសារៈសំខាន់ណាស់ ដែលសិស្សទាំងអស់គ្នាទទួលបានការកោតសរសើរចំពោះការច្នៃប្រឌិត ចំណែកឯប្រតិកម្មទទួលបានយោបល់ជាវិជ្ជមាន។

ស្នើសិស្សទាំងអស់គ្នា ជៀសវាងប្រើពាក្យថា *ខុស* សម្រាប់ "ដំបូន្មាន" និងស្នើសុំផងដែរអំពីប្រតិកម្ម "ល្អ"។

## សេចក្ដីណែនាំគ្រូ

ជាការពិត សិស្សទាំងអស់គ្នាមិនមានការសន្សំសំចៃទេ គឺពួកគេអាចប្រើប្រាស់ដើម្បីចាប់ផ្ដើម នូវសហគ្រាសរបស់ពួកគេបាន។ ពួកគេត្រូវការគិតអំពីមធ្យោបាយក្នុងការខ្ចីសម្ភារៈ ដោយមិនមានការគិតថ្លៃ ឬក៏ជ្រើសរើសនូវសហគ្រាសមួយដែលមិនត្រូវការលុយក្នុងការចាប់ផ្ដើមបង្កើត សហគ្រាស។ ពួកគេក៏អាចធ្វើការសម្រេចចិត្តផងដែរ ដើម្បីដាក់លុយមួយចំនួនដែលបានមកពីខ្លួនគេផ្ទាល់ ក៏ប៉ុន្តែបន្ទាប់មកគ្រប់ៗគ្នាគួរតែធ្វើការជួយឧបត្ថម្ភផងដែរ។

# សហគ្រាសសង្គម និងកុមារ

ក្នុងចំណោមអ្នកទាំងអស់គ្នា តើមានអ្នកជាប់ទាក់ទងក្នុងការបង្កើតសហគ្រាស កាលពីឆ្នាំមុនដែរឬទេ?តើការងារដែលអ្នកកំពុងធ្វើទទួលបានប្រាក់កម្រៃល្អដែរឬទេ ?

ខ្ញុំគិតថា វាគឺជាពេលវេលាមួយដែលយើងត្រូវតែមើល បទពិសោធន៍ក្នុងការធ្វើការងារជាក្រុមរបស់អ្នក ។ ចូរព្យាយាមធ្វើការពិភាក្សាគ្នាជាក្រុម នូវចម្លើយទៅនឹងសំណួរខាងក្រោម ។



១. តើប្រភេទការងារអ្វីដែលអ្នកកំពុងធ្វើ?

២. តើអ្នកមានអារម្មណ៍ដូចម្តេច នៅពេលដែលបានធ្វើការងារនេះ ?

៣.តើនរណាដែលបានបង្កើតនូវជំនួញផ្ទាល់ខ្លួនរបស់ពួកគេកាលពីពេលមុន ?

៤. តើអ្នកមានបានទទួលនូវប្រាក់ចំណេញដែរឬទេ ?

៥. តើអ្នកទទួលបានប្រាក់ចំណេញចំនួនប៉ុន្មាន?

៦. ប្រសិនបើអ្នកមិនទទួលបាននូវប្រាក់ចំណេញ តើអ្វីដែលអ្នកគិតថា ខុសឆ្គង?

៧. តើអ្នកមានការភ័យខ្លាចនូវចំណុចណាមួយដែរឬទេ ?

៨. តើអ្នកមានអារម្មណ៍ថា មានផាសុខភាពឬទេចំពោះការគ្រប់គ្រងលុយ?

៩. តើអ្នកត្រូវការខ្ចីលុយដែរឬទេ?

ទាំងអស់គ្នារួមជាមួយនឹងក្រុមរបស់អ្នក ចូរផ្តល់គំនិតចំនួនបីដែលអ្នកបានផ្លាស់ប្តូរនៅក្នុងរបៀបដែលអ្នកធ្វើការឬក៏ការអនុវត្តចំពោះរបស់អ្នក ។

ចូរសរសេរដំបូន្មានដែលសំខាន់បំផុតចំនួនបី សម្រាប់សិស្សដទៃ



# សហគ្រាសសង្គម និងកុមារ



## គិតពីវា

ឯកសារនេះ អ្នកអាចពិនិត្យមើលអំពីការធ្វើសហគ្រាស ដែលត្រូវផ្ទួសបន្ទាយពេលវេលារហូតដល់១០ សប្តាហ៍ ។ គំនិតមួយចំនួនអាចជារបស់អ្វីមួយដែលអ្នកអាចធ្វើ ក្នុងពេលទំនេររបស់អ្នក រោងសាលា និងការងារដទៃទៀត ។



ការប្រមូល ហើយនិងការលក់
ក្រដាសចាស់ៗ ថង់ប្លាស្ទិច ឬក៏កំប៉ុង



ការផលិត និងការលក់ស្ករគ្រាប់
ទឹកកក ឬគេសជ្ជៈ



ឬក៏..

?

ធ្វើកងដៃ ឬខ្សែក ធ្វើពីប្លាស្ទិច
ឬក៏ ខ្សែអំបោះដើម្បីលក់

# អនុវត្ត

១.ចូរធ្វើការគិតរយៈពេលពីរឬបីនាទី អំពីសហគ្រាសណាមួយដែលអ្នកអាចបង្កើតបាន ហើយសរសេរពួកវា ។ បន្ទាប់មក បង្ហាញពីគំនិតរបស់អ្នកដល់ក្រុម ។ ចូរចងចាំៈ រាល់សមាជិកទាំងអស់ត្រូវតែអាចប្រាប់ពីអ្វីដែលពួកគេបាន សរសេរ ។

២.ចូរធ្វើការពិភាក្សាជាមួយនឹងសមាជិកដទៃទៀតស្តីអំពីអ្វីដែលក្រុមចូលចិត្តធ្វើ និងបង្កើតនូវគម្រោងដោយការប្រើប្រាស់នូវអ្វីៗដែលអ្នកបានរៀននៅក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយស្តីអំពីលុយ។ វិធីសំខាន់ៗមួយចំនួនដែលត្រូវធ្វើការអនុវត្តតាម នៅអំឡុងពេលដែលអ្នកកំពុងធ្វើការសម្រេចចិត្តគឺៈ

- តើវាត្រូវចំណាយរយៈពេលប៉ុន្មាន?
- តើវាមានលក្ខណៈពិបាកឬទេ ដើម្បីធ្វើវា នៅក្នុងរយៈពេល១០សប្តាហ៍?
- តើវាមានលក្ខណៈពិបាកឬទេ ដើម្បីធ្វើ?
- តើអ្នករាល់គ្នាដែលនៅក្នុងក្រុម អាចធ្វើការឧបត្ថម្ភចំពោះសហគ្រាសនេះបានដែរឬទេ?
- តើយើងអាចធ្វើការលក់បានឬទេ នូវអ្វីដែលបានផលិត?
- តើនរណាជាអ្នកទិញវា?
- តើយើងអាចមានការបាត់បង់ឬទេ ចំណាប់អារម្មណ៍ចំពោះវាឬទេ បន្ទាប់ពីធ្វើវាម្តង?

នេះជាសំណួរមួយចំនួនដែលយើងត្រូវឆ្លើយមុនពេលដែលយើងចាប់ផ្តើមនូវគម្រោងនេះ។

បន្ទាប់ពីពិភាក្សា ចូររៀបចំធ្វើការពន្យល់នូវគំនិតរបស់អ្នកទៅកាន់ក្រុមដទៃទៀត ។គ្រូរបស់អ្នកនឹងប្រាប់អ្នកនៅពេលដែលអ្នកត្រូវធ្វើការពន្យល់ ។



មកដល់ពេលឥឡូវនេះ អ្នកទទួលបានមតិពីក្រុមដទៃ ។ ធ្វើការផ្តល់អាទិភាព ដោយបង្កើតជាបញ្ជីមួយសំរាប់អ្វីដែលគួរធ្វើចំនួន៥ និងអ្វីដែលមិនគួរធ្វើចំនួន៥ដែលសំខាន់បំផុត ។

អបអរសាទរ ដែលអ្នកត្រៀមរួចរាល់ចំពោះ ការបង្កើតនូវគម្រោងមុខជំនួញ ។ ចូរធ្វើការប្រាកដប្រជាថា អ្នកអាចដាក់នូវរាល់ព័ត៌មានទាំងអស់នៅកន្លែងដែលអាចរក្សាសុវត្ថិភាពបាននៅក្នុងថ្នាក់រៀន។ អ្នកនឹងត្រូវការវាសម្រាប់ពេលក្រោយទៀត ។

ឥឡូវសូមធ្វើការអនុវត្តបន្តិច...

## សហគ្រិន

អ្នកបានធ្វើការសម្រេចចិត្តដើម្បីធ្វើការដាំស្រូវ និងទិញគ្រាប់ពូជដែលមាននៅឯផ្សារ ។ ពីមុនវាមានតម្លៃថោក ក៏ប៉ុន្តែឥឡូវអ្នកលក់បានបង្កើនតម្លៃរបស់វាទ្វេជាពីរ! អ្នកក៏ដឹង ផងដែរថានៅកន្លែងដទៃគឺមានតម្លៃថោកជាង។

## អតិថិជន

អ្នកជាអ្នកលក់គ្រាប់ពូជស្រូវ ហើយអ្នកដឹងថាសហគ្រិនមានលុយច្រើន។ អ្នកក៏ព្យាយាមលក់គ្រាប់ពូជទាំងនោះក្នុងតម្លៃទ្វេជាពីរ។ ត្រូវតែមានលំនឹង!



## សហគ្រិន

អតិថិជនម្នាក់បានយកវិទ្យុមួយគ្រឿងដែលគាត់បានចំណាយ២០ដុល្លារទិញវាពីកន្លែងរបស់អ្នកពីរថ្ងៃមកហើយ។ គាត់និយាយថា វាមិនដំណើរការទេ។ ក៏ប៉ុន្តែអ្នកបានឃើញថាវិទ្យុនោះត្រូវបានធ្វើឲ្យបើក ហើយខ្សែមួយចំនួនក៏បានប្តូរ។ វិទ្យុគឺវាបានខូច



## អតិថិជន

អ្នកបានធ្វើឲ្យវិទ្យុខូចដោយសារតែអ្នកបានដោះវាចេញ និងបានធ្វើឲ្យខូចនូវខ្សែភ្លើងមួយចំនួនទៀត។ ចូរធ្វើការព្យាយាមធ្វើដំណើរ ត្រលប់ទៅហាងវិញ ហើយយកលុយរបស់ អ្នកមកវិញ។ ដោយនិយាយទៅកាន់ពួកគេថាអ្នកគ្រាន់តែព្យាយាមជួសជុលវាតែប៉ុណ្ណោះ។

## សហគ្រិន

អ្នកបានធ្វើការបង្កើតនូវក្រុមហ៊ុនមួយដែល អនុញ្ញាតឱ្យប្រជាជនធ្វើការខ្ចីប្រាក់ក្នុងបរិមាណដ៏តិចមួយ។ អ្នកគ្រាន់តែផ្តល់នូវកម្ចីទៅប្រជាជនដែលមិនមានជំពាក់បំណុល ! ឥឡូវនេះ មិត្តរបស់អ្នកបានមកដល់។ គាត់បានជំពាក់បំណុលគេជាច្រើនដោយសារតែគាត់លេងល្បែង។គាត់ចង់ខ្ចីលុយមួយចំនួន

## អតិថិជន

អ្នកគឺជាមិត្តភក្តិមួយរូបរបស់សហគ្រិន និងចូលចិត្តលេងល្បែងខ្លាំងណាស់។ អ្នកចង់ខ្ចីលុយចំនួន១០ដុល្លារ ហើយអ្នកប្រាប់សហគ្រិនថា អ្នកនឹងយកលុយទាំងអស់នោះទៅទិញម្ហូបអាហារសម្រាប់ក្រុមគ្រួសាររបស់អ្នក ក៏ប៉ុន្តែអ្វីដែលនិយាយទាំងអស់នោះ គឺសុទ្ធតែមិនមែនជាការពិត

# មេរៀនទី ២: ជំនួញធំ

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរកិច្ចតែងការបង្រៀន
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេ
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)



📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- សន្លឹកកិច្ចការ២.១
- សៀវភៅសម្រាប់កត់ត្រាមួយ ដែលអាចប្រើប្រាស់ជាសៀវភៅសម្រាប់កត់ត្រាចំនួនលុយ

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- អនុវត្តន៍ធ្វើការងារជាមួយគ្នា នៅពេលដែលកំពុងស្តាប់និងធ្វើការអង្កេតមើល
- បង្កើតនូវគម្រោងជំនួញ និងសម្រុះសម្រួលការប្រើប្រាស់លទ្ធផលនេះពីសិស្សដទៃៗទៀត
- ដោះស្រាយបញ្ហា ដោយការប្រើប្រាស់ស្ថានការបែបសន្មត
- វិភាគនូវគំនិត និងគម្រោងទៅលើចំណុចខ្លាំង និងខ្សោយ
- ការប្រើប្រាស់ល័ក្ខខ័ណ្ឌដែលផ្តល់ឱ្យជាមូលដ្ឋាន ដើម្បីសង្ខេបនូវកិច្ចការ និងឧបករណ៍ប្រើប្រាស់នានា។

**ចំណាងជើងមេរៀនទី ២: ជំនួញធំ** 🕑 ១០ នាទី

**សកម្មភាពទី១៖ សេចក្តីផ្តើម**

សិស្សទាំងអស់គ្នាអាចដើរពាសពេញថ្នាក់រៀនដោយមិនឱ្យប៉ះអ្វីមួយ ឬក៏នរណាម្នាក់។ ប្រសិនបើពួកគេស្វែងរក ឃើញថាការធ្វើដូច្នេះមានលក្ខណៈពិបាក អ្នកអាចធ្វើការទះដៃបន្ទរជា សំឡេង ដែលពួកគេត្រូវតែធ្វើតាម។ បន្ទាប់ពី នោះមក គ្រូស្រែកប្រាប់ "ពីរ ឬបីដង"។ សិស្សទាំងអស់ បង្កើតជាក្រុមដែលអាចមានសមាជិក ២ឬ៣នាក់ (ឬក៏ច្រើនជាងនេះ) ក្នុងមួយក្រុមៗ។ បន្ទាប់មក អ្នកស្រែកប្រាប់នូវពាក្យ" មុខរបរ" ដូចជា វេជ្ជបណ្ឌិត ពេទ្យធ្មេញ គ្រូបង្រៀន កសិករ អ្នកលក់ទឹកកក។ល។ សិស្សទាំងអស់គ្នានឹងត្រូវធ្វើជារូបចម្លាក់មួយដែលតំណាងឱ្យមុខរបរនោះ ឬក៏អ្វីៗផ្សេងទៀតដែលជាប់ទាក់ទង។

បន្ទាប់មក អ្នកអាចផ្លាស់ប្តូរល្បែងនេះបន្តិច។ ដោយឥឡូវ អ្នកចង់ឱ្យសិស្សបង្កើត រូបចម្លាក់ពណ៌នាអំពីមុខរបរដែលជាប់ទាក់ទងគ្នាទៅវិញទៅមក។ ឧទាហរណ៍ នៅពេលដែលអ្នកស្រែកថា "គ្រូ" ដូច្នេះម្នាក់ នៅក្នុងចំណោមពួកគេគឺជាគ្រូ ហើយចំណែកឯអ្នកដទៃទៀត គឺជាលោកនាយក សិស្ស។ល។

នៅពេលដែលអ្នកបានកត់សម្គាល់ឃើញនូវឧទាហរណ៍ល្អមួយ អ្នកអាចអញ្ជើញសិស្សដទៃទៀតឱ្យនៅ "មានចលនា" និងក្រឡេកមើលទៅរូបចម្លាក់ពណ៌នាអំពីមុខរបរនោះ។ ចូរផ្តោតទៅលើសហប្រតិបត្តិការ។ សួរសិស្សទាំងឡាយថា " តើមនុស្សទាំងអស់នេះធ្វើការ ជាមួយគ្នាដូចម្តេចដែរ?"

## សកម្មភាពទី ២ : ការបង្កើតជំនួញ

៦០ នាទី

អនុញ្ញាតឱ្យសិស្សរំឭកឡើងវិញនូវអ្វីដែលពួកគេបានធ្វើកាលពីសប្តាហ៍មុន។

ចូរបន្តរៀបចំពួកគេសម្រាប់ថ្ងៃនេះ។"យើងនឹងបង្កើតនូវគម្រោងមួយសម្រាប់សហគ្រាសរបស់ពួកយើង ហើយនឹងចាប់ផ្តើមធ្វើការរកលុយ "។

អ្នកព្រមទាំងសិស្សទាំងអស់គ្នា ក្រឡេកមើលក្រដាស ដែលអាចមាននូវកំហុសមួយ ចំនួន ដែលអ្នកបានសរសេរចូលកាលពីសប្តាហ៍មុន។ យកវាទៅព្យួរនៅលើជញ្ជាំង។ សិស្សទាំងអស់ត្រូវនាំគ្នាគិតអំពីដំណោះស្រាយណាមួយដែលអាចកើតមាន។

ប្រសិនបើអ្នកមានក្តារខៀនពណ៌ស ឬក៏ដីស ចូរឱ្យពួកគេគូសភ្ជាប់នូវចំណុចដំណោះស្រាយទៅនឹងបញ្ហា ដូចឧទាហរណ៍ខាងក្រោមៈ

កំហុសដែលបានបង្កើតជម្មតា
១. បញ្ហាទី១ → ដំណោះស្រាយ
២. បញ្ហាទី២ → ដំណោះស្រាយ

ចូរប្រាប់សិស្សឱ្យត្រលប់ទៅរកក្រុមរបស់ពួកគេវិញ ហើយផ្តល់ឱ្យពួកគេនូវការងារជាមួយ នឹងឯកសារ ២.១ សម្រាប់សិស្ស" គម្រោងនៃការធ្វើជំនួញ "។ គម្រោងនេះផ្តោតទៅលើការរៀបចំសហគ្រាសរបស់ពួកគេ។ ចូរពន្យល់ទៅលើសន្លឹកកិច្ចការ ដែលមាននៅលើក្តារខៀន។

ចូរសរសេរចូលក្នុងតារាងដែលបានមកពីក្រដាសកិច្ចការ និងពាក្យទាំងឡាយដែលបានគូសបន្ទាត់ពីក្រោម

| ចំនួន | ការងារដែលបានធ្វើ | តើអ្វីខ្លះដែលយើងត្រូវការ? | ពេលវេលា | តើនរណាដែលនឹងធ្វើវា? | បានធ្វើ |
|---|---|---|---|---|---|
| ផ្តល់ឱ្យកិច្ចការនីមួយៗនូវលេខចំនួនមួយ | សរសេរចូលនូវកិច្ចការជាល្បះពេញលេញច្បាស់លាស់។ ឧទាហរណ៍ ៖ "ត្រូវការទិញពែងជ័រ ចំនួន ១០០។" | តើអ្វី ខ្លះដែលចាំបាច់ត្រូវធ្វើ<u>ការងារ</u>? | តើវាត្រូវចំណាយរយៈពេលប៉ុន្មានក្នុងការធ្វើកិច្ចការនេះ? | សម្រេចចិត្តថា នៅក្នុងក្រុមតើនរណាដែល សមស្របបំផុតចំពោះការងារនេះ ដោយផ្អែក ទៅលើចំណាប់អារម្មណ៍ និងបទពិសោធន៍ | ដាក់សញ្ញាសម្គាល់ នៅពេលដែលបញ្ចប់ការងារ |

សិស្សទាំងអស់គ្នា ត្រូវបំពេញក្នុងតារាងការងារខាងលើជាមួយគ្នា ហើយភ្ជាប់វាទៅនឹង ជញ្ជាំង។ នៅសប្ដាហ៍ ក្រោយ ពួកយើងត្រូវដាក់សញ្ញាសម្គាល់ សម្រាប់ការងារណាដែលបានធ្វើរួចរាល់ ហើយបន្ថែមការងារណា ដែលទើបតែមាន។ នៅក្នុងមេរៀនទី៤នេះយើងនឹងនិយាយឡើងវិញ ព្រមទាំងវាយតម្លៃតារាងការងារនេះ។

ក្រុមនឹងតម្រូវឱ្យបំពេញក្នុងទម្រង់មួយនេះ ឱ្យបានច្បាស់លាស់។ ដូច្នេះគ្រូត្រូវការត្រួតពិនិត្យមើល ប្រសិនបើការពណ៌នាអំពីការងាររបស់ពួកគេ មានភាពច្បាស់លាស់និងតម្រូវការដែលបានធ្វើការប៉ាន់ប្រមាណរបស់ពួកគេ ព្រមទាំងពេលវេលាក៏ត្រូវមានភាពប្រាកដប្រជាផងដែរ។ សិស្សមានរយៈពេល៣០នាទីដើម្បីធ្វើការបំពេញនូវទម្រង់ មួយនេះ។

ប្រសិនបើពួកគេបានធ្វើរួចរាល់ ក្រុមទាំងអស់ត្រូវជ្រើសរើស *អ្នករិះគន់ចំនួន ២នាក់* ដើម្បីពិនិត្យមើលគម្រោងសម្រាប់ធ្វើជំនួញដទៃៗ។

នៅរៀងរាល់រយៈពេល២នាទី អ្នករិះគន់ ធ្វើដំណើរទៅកាន់ក្រុមដទៃទៀត និងវិភាគទៅលើគម្រោងជំនួញដូចជាៈ

- បញ្ហាដែលអាចកើតមាន
- ចំណុចខ្លាំង
- ដំបូន្មានទៅលើគម្រោង ។

ចំណែកឯសិស្សពីរនាក់ផ្សេងទៀតមកពីក្រុម សរសេរចូលនូវមតិយោបល់ ដែលផ្ដល់ដោយអ្នករិះគន់។ក្រុមនីមួយៗត្រូវតែសម្រេចចិត្តថា តើការផ្លាស់ប្ដូរណាមួយដែលពួកគេត្រូវ តែបង្កើតឡើងចំពោះគម្រោងរបស់ពួកគេ ដោយពឹងផ្អែកទៅលើមតិយោបល់របស់អ្នករិះគន់។ បន្ទាប់ពីផ្លាស់ប្ដូរគម្រោងរបស់ពួកគេ យើងត្រូវការបង្កើត ប្រព័ន្ធសន្សំសុវត្ថិភាព និងធម្មតាមួយ។

នៅលើតុ មានសៀវភៅសម្រាប់ធ្វើការកត់ត្រាលុយមួយផងដែរ។ រៀងរាល់ថ្ងៃនៅ ពេលនេះ (អាចធ្វើការជ្រើសរើសយកពេលវេលា និងថ្ងៃល្អ) អ្នកអាចធ្វើដំណើរមកកាន់ថ្នាក់រៀន ជាមួយនឹងនរណាម្នាក់ក៏បាន ដែលមកពីក្រុមរបស់អ្នក ហើយប្រគល់លុយដែលអ្នករកបាន។បន្ទាប់មកលុយរបស់អ្នកនឹងត្រូវបានរក្សាទុក នៅក្នុងការិយាល័យរបស់លោកនាយក ដូច្នេះវាមានសុវត្ថិភាពល្អ។ ជារៀងរាល់សប្ដាហ៍យើងនឹងរាប់លុយដែលយើងរកបានសម្រាប់ក្រុមនីមួយៗហើយកត់ត្រាទុកនៅក្នុងសៀវភៅកត់ត្រាលុយ។

## សកម្មភាពទី ៣ៈ មតិរិះគន់ដែលអាចមើលឃើញ

🕑 ២០ នាទី

✋ គ្រូនិងសិស្សឈរជារង្វង់ ដើម្បីឱ្យពួកគេមានចំណាប់អារម្មណ៍ យើងនឹងនាំគ្នាលេងល្បែងមួយ ដែលគេហៅថា "ទះដៃទៅមក"

មានមនុស្សម្នាក់ដែលត្រូវបានជ្រើសរើសដើម្បីចាប់ផ្ដើមលេងល្បែងនេះ។ គេ បែរទៅខាងស្ដាំ ហើយ ទះដៃរបស់គេ។ នៅពេលដែលគេធ្វើ ដូច្នេះ មនុស្សម្នាក់ទៀតដែលស្ថិតនៅចំហៀងគាត់បែរទៅខាងស្ដាំដៃរបស់គេ ហើយ "ទទួល" យកនូវការទះដៃដោយ ធ្វើការទះដៃក្នុងពេលតែមួយ។ បន្ទាប់មក គេអាចធ្វើការឆ្លងកាត់នូវល្បែងនេះបាន ហើយអ្នកក៏អាចបន្ថែមល្បឿនទៅលើល្បែងនេះទៀតក៏បានដែរ។

រយៈពេល១០នាទីក្រោយមក អ្នកធ្វើការពន្យល់ ៖

ខ្ញុំចង់ឱ្យអ្នកទាំងអស់គ្នា គិតដោយយកចិត្តទុកដាក់អំពីកិច្ចការរបស់ពួកយើង នៅក្នុងសហគ្រាសរបស់ក្រុម។ ខ្ញុំនឹងធ្វើការហៅឈ្មោះ បន្ទាប់មកបុគ្គលនោះ ត្រូវ ធ្វើដំណើរមួយជំហានទៅមុខ ហើយធ្វើគ្រាប់តាមសកម្មភាព ដែលគាត់នឹងកំពុងធ្វើដោយការនិយាយ។

ឧទាហរណ៍ សុភាព ត្រូវការផ្តល់ឱ្យក្រុមរបស់គេនូវកាបូបដើម្បីប្រមូលកំប៉ុង។ គេក៏បានធ្វើដំណើរមួយ ជំហានទៅមុខ ដោយធ្វើសកម្មភាពដូចជាចង់រើសកាបូប ក្រោយមក ប្រាប់ទៅកាន់ក្រុមថា "ខ្ញុំនឹងឱ្យកាបូបទាំងអស់នេះទៅក្រុមរបស់ខ្ញុំ។"

មុនពេលដែលសិស្សទាំងអស់គ្នាចាកចេញពីថ្នាក់ ចូរនិយាយប្រាប់ឡើងវិញនូវ កាលបរិច្ឆេទ ដែលសហគ្រាសរបស់ពួកគេចាប់ផ្តើម និងពេលគម្រោងត្រូវបានបញ្ចប់។ នោះនឹងត្រូវធ្វើឡើងនៅក្នុងមេរៀនទី៧ រយៈពេល៥សប្តាហ៍។

ចូរកត់ចំណាំក្រោយៗដំណើរការ និងរៀបចំសញ្ញាសម្គាល់។ យើងអាចមានទង់ជាតិបញ្ចប់មួយដែលមានកាលបរិច្ឆេទនៅលើវាផងដែរ ឬក៏អាចមានជាសញ្ញាឈប់ដ៏ធំមួយ ដោយមាននូវកាលបរិច្ឆេទនៅពីក្រោមវាផងដែរ។

## សេចក្តីណែនាំគ្រូ

- ចូរពិភាក្សាជាមួយនិងលោកនាយកស្តីអំពីប្រព័ន្ធសន្សំសំចៃ។ លោកនាយកអាចសន្សំលុយនៅក្នុងកន្លែងដែលអាចចាក់សោបាន
- នៅក្នុងមេរៀននេះ សិស្សទាំងអស់គ្នាត្រូវបង្កើតគម្រោងចុងក្រោយមួយសម្រាប់សហគ្រាសរបស់ពួកគេ។ សម្រាប់ក្រុមមួយចំនួនវិញ ចំពោះបញ្ហានេះអាចមានលក្ខណៈលំបាក។ ចំពោះគំនិតមួយចំនួនទៀត ដែលមានសម្រាប់សហគ្រាសតូចៗគឺៈ
  - រៀបចំហាងតូចមួយ ដែលជាកន្លែងលក់របស់របរមួយចំនួនដោយអ្នកមិនត្រូវការអ្វីបន្ថែមទៀតទេ
  - ជួលអ្នកណាម្នាក់ពីសហគមន៍ ឬក៏ក្រុមគ្រួសាររបស់អ្នកដោយយកថ្លៃឈ្នួលដ៏តិចតួច
  - ផលិតប្រដាប់ប្រដាក្មេងលេង ឬក៏គ្រឿងអលង្ការដែលធ្វើដោយដៃ សម្រាប់លក់
  - រៀបចំម្ហូបអាហារ ឬក៏របស់របរពិសេសណាមួយ ដែលអាចយកទៅលក់នៅទីផ្សារ ឬក៏តាមផ្លូវ
  - ប្រមូលកំប៉ុង ឬក៏ក្រដាសកាសែតចាស់ៗ
  - បង្កើតនូវក្រុមហ៊ុនលាងឡាន ឬម៉ូតូ
  - ធ្វើជាអ្នកមើលក្មេងឱ្យសមាជិកគ្រួសារ ឬក៏មិត្តភក្តិ
  - សំអាតផ្ទះ ឬផ្លូវ ដោយយកប្រាក់កម្រៃតិចតួច
  - រៀបចំពេងមហោស្រពសម្រាប់ការប្រគំតន្ត្រី ហើយយកថ្លៃចូលទស្សនា។

# ត្រៀមរួចជាស្រេចដើម្បីធ្វើ

ចូរសរសេរចូលនូវប្រភេទសហគ្រាសអ្វី ដែលក្រុមរបស់អ្នកនឹងធ្វើការចាប់ផ្តើម

| ល.រ | តើការងារអ្វីខ្លះ? | តើយើងត្រូវការអ្វី? | ម៉ោង | តើនរណានឹងធ្វើវា? | បានសម្រេច |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

# មេរៀនទី ៣: ការងារសកល

រយៈពេលបង្រៀន: ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូរ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន ( តុ កៅអី ក្តារខៀន...)

សម្ភារៈឧបទេស ធនធានដែលត្រូវការ

ផ្ទាំងរូបភាពនៃ "អនុសញ្ញាស្តីអំពីសិទ្ធិរបស់កុមារ"

វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ផ្តល់តម្លៃចំពោះពេលវេលារបស់ពួកគេ ដែលបានចំណាយទៅលើការធ្វើការងារការទៅសាលារៀន និងពេលទំនេរ
- អនុវត្តទម្លាប់ និងរចនាសម្ព័ន្ធទាំងឡាយរបស់ពួកគេ ដែលមានទំនាក់ទំនងជាមួយសិស្សដទៃ
- កំណត់អត្តសញ្ញាណអំពីស្ថានភាពសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា
- បង្ហាញច្បាស់អំពីភាពខុសគ្នារវាងពេលទំនេរ ការងារ និងពលកម្មកុមារ
- មានការយល់ដឹងជាមូលដ្ឋានអំពីភាពមានស្រាប់ និងខ្លឹមសាររឿងនៃសិទ្ធិកុមារ ។

**ចំណាងជើងមេរៀនទី ៣: ការងារសកល** ២០ នាទី

**សកម្មភាពទី១ សេចក្តីផ្តើម: ល្បែងគូរ**

គ្រូជ្រើសរើសសិស្សចំនួន៥នាក់ ហើយឱ្យដីសទៅពួកគេ។ ដោយប្រាប់ថាអ្នកមានរយៈពេលមួយនាទីក្នុងការគូរនូវសកម្មភាពរបស់ពួកគេតាំងពីថ្ងៃនោះ រហូតមកដល់ពេលឥឡូវ។

ខ្ញុំចង់ឱ្យអ្នកគូរពីសកម្មភាព ដែលអ្នកបានធ្វើនៅក្នុងថ្ងៃនេះ។ អ្នកមិនចាំបាច់សរសេរជាតួអក្សរទេក៏ប៉ុន្តែអ្នកត្រូវតែដាក់សកម្មភាពរបស់អ្នកតាមលំដាប់។ រយៈពេលមួយនាទីក្រោយមក គ្រូវប្រាប់ពួកគេឱ្យឈប់សិន ហើយអញ្ជើញសិស្សដទៃទៀតមក ធ្វើការពន្យល់នូវអ្វីដែលគេបានធ្វើ។ អ្នកអាចធ្វើដូច្នេះបានម្តងទៀតជាមួយសិស្សដទៃទៀត។

បន្ទាប់មក អ្នកអាចសរសេរនៅលើក្តារខៀន។ អនុញ្ញាតឱ្យសិស្សទាំងអស់គ្នា ពិភាក្សាលើសកម្មភាពមួយណាដែលបង្ហាញអំពីពេលទំនេរ និងមួយណាដែលបង្ហាញ អំពីការងារ។ បន្ទាប់ពីពួកគេបានបែងចែកសកម្មភាពទាំងឡាយ ហើយចូរព្យាយាមបំពេញក្នុងបញ្ជីបន្ថែមទៀត។

| ពេលទំនេរ | ការងារ |
|---|---|
| មើលទូរទស្សន៍<br>លេងកីឡាវាយសី<br>សម្រាក<br>ដើរលេងនៅសួនឧទ្យាន<br>លេងជាមួយមិត្តភក្តិ | បោកគក់សំលៀកបំពាក់<br>ទិញអាហារនៅឯហាង<br>ជួយធ្វើការងារឪពុកម្តាយ<br>នៅឯចំការ |

អ្នកទាំងអស់គ្នា ចូរគិតអំពីអ្វីដែលបង្ហាញពីពេលទំនេរ និងអ្វីដែលបង្ហាញពីការងារ។
ពេលទំនេរ គឺនិយាយអំពីជម្រើសផ្ទាល់ខ្លួន ចំណែកឯការងារ គឺនិយាយអំពីសកម្មភាពដែលត្រូវតែធ្វើ។

## សកម្មភាពទី២ សកម្មភាពចម្បង

🕑 ៦០ នាទី

ចូរចែកក្រដាសសឱ្យសិស្សសរសេរ ឬឱ្យសិស្សសរសេរនៅក្នុងសៀវភៅកត់ត្រារបស់ពួកគេ។

រាល់សិស្សទាំងអស់ ចូរបង្កើតនូវតារាងពេលវេលាផ្ទាល់ខ្លួនម្នាក់មួយ ដែលបង្ហាញពីសកម្មភាពប្រចាំថ្ងៃ។ ពួកគេចាប់ផ្តើម សរសេរពីពេលវេលា ដែលពួកគេក្រោកពីដំណេក។ បន្ទាប់មក ពួកគេត្រូវសរសេរជាបន្តបន្ទាប់នូវសកម្មភាពដែលពួកគេបានធ្វើក្នុងពេលកំណត់នីមួយៗ។

ឧទាហរណ៍ ៖៦:០០ : ក្រោកពីដំណេក
៦:១៥ : សម្អាតខ្លួនប្រាណ
៦:៣០ : ញ៉ាំអាហារពេលព្រឹក
៧:០០ : សាលាចាប់ផ្តើមចូលរៀន
៨:០០ : ម៉ោងគណិត...
១១:០០ : លេងជាមួយស្រីយ៉ាននៅលើទីវាល
១២:០០ :

គ្រូបង្កើតក្រុមពិភាក្សាដែលមានគ្នាបីនាក់។

ក្រុមនីមួយៗ ត្រូវតែពិនិត្យមើលតារាងពេលវេលារបស់ពួកគេ ហើយរាប់ចំនួនម៉ោងដែលពួកគេបានចំណាយពេលវេលាទៅលើសកម្មភាពខុសៗគ្នាទាំងទាំងអស់នោះ។

ឧទាហរណ៍ ការងារផ្ទះ កីឡា ការសិក្សានៅចុងបញ្ចប់ គ្រូឱ្យសិស្សរាប់ចំនួនម៉ោងធ្វើការ និង ពេលទំនេរ។ ចូរបង្ហាញពីភាពខុសគ្នា រវាងតារាងពេលវេលារបស់សិស្សផ្សេងៗគ្នា

ចូរផ្ដល់ឱ្យនូវឯកសារទី៣ សម្រាប់សិស្ស ហើយឱ្យសិស្សអនុវត្តជាមួយនឹងករណីសិក្សាទី១។ រយៈពេល៣០នាទីក្រោយមក ចូរប្រមូលកិច្ចការសិស្សទាំងអស់គ្នា។

ចូរសាកសួរទៅកាន់សិស្សពី ឬបីនាក់អំពីការស្វែងរករបស់ពួកគេ។

ឧទាហរណ៍ តើការជួយរបស់ស្រីយ៉ា មានផលប៉ះពាល់ជាវិជ្ជមានអ្វីខ្លះ ដែលក្រុមរបស់អ្នកបានស្វែងរកឃើញ?

តើលទ្ធផលអវិជ្ជមាន នៃការស្នាក់នៅផ្ទះរបស់នាង មានអ្វីខ្លះ?

ចូរធ្វើការសាកសួរទៅកាន់សិស្សម្នាក់ៗ ពីគំនិតរបស់ពួកគេ ទាក់ទងទៅ នឹងសំណួរចុងក្រោយ។ នៅពេលដែលពួកគេផ្ដល់ចម្លើយ ចូរធ្វើការសាកសួរពួកគេនូវហេតុផលមួយចំនួនផងដែរ។ ចូរឱ្យពួកគេគិតអំពីចម្លើយរបស់ពួកគេផងដែរ។ ឧទាហរណ៍ ហេតុអ្វីបានជាអ្នកគិតថា សិស្សភាគច្រើននាំគ្នានិយាយថានៅអាយុ១២ឆ្នាំ គឺជាអាយុដែលល្អដើម្បីចាប់ផ្ដើម រៀនចម្អិនម្ហូបអាហារ?

រាល់ក្មេងៗទាំងអស់ គឺមានសិទ្ធិទៅសាលារៀន។ អង្គការសហប្រជាជាតិ ជាអង្គការមួយដែលប្រទេសស្ទើរទាំងអស់ក្នុងពិភពលោក មានប្រទេសកម្ពុជាផងដែរ គឺបានធ្វើការជាមួយគ្នាហើយ បង្កើតនូវឯកសារដ៏សំខាន់មួយ។ បង្ហាញប័ណ្ណប្រកាសស្ដីពី*អនុសញ្ញានៃសិទ្ធិកុមារ* ។ចូរធ្វើការដាក់ពណ៌ពីលើពាក្យថា*សិទ្ធិក្នុងការទៅសាលារៀន* និងពាក្យ *គ្មានកុមារណាដែលត្រូវបានកេងប្រវ័ញ្ចចំពោះការងារ*។

ចូរបន្ថែមជួរដេកមួយទៀតសម្រាប់ផ្នែក *ពេលទំនេរ* និង *ការងារ*។ ត្រូវបង្ហាញភាព ខុសគ្នារវាង *ធ្វើការ ដោយជួយ* និង *ពលកម្មកុមារ*។ សិស្សទាំងអស់ នាំគ្នាគិតរកឧទាហរណ៍ល្អៗនៃការជួយក្រុមគ្រួសាររបស់អ្នក ក៏ប៉ុន្តែ អ្នកនៅតែអាចទៅរៀនបាន ហើយយើងក៏ផ្ដល់ឧទាហរណ៍មិនល្អ ដែលកុមារមិនអាចទៅរៀនបាន និងត្រូវបានធ្វើការ បង្ខិតបង្ខំផ្នែកពលកម្មផងដែរ។

**សកម្មភាពទី៣ បញ្ចប់មេរៀន** ⌚ ១០ នាទី

សិស្សទាំងអស់គ្នា ត្រូវបានឱ្យធ្វើការអង្កេតទៅលើអត្ថបទកាសែត និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ចំពោះឧទាហរណ៍ល្អ និងមិនល្អដែលជាប់ទាក់ទងទៅនឹងសិទ្ធិកុមារ។ ពួកគេគូររូបទឹកមុខសប្បាយ☺ នៅលើឧទាហរណ៍ល្អ និងទឹកមុខមិនសប្បាយ☹ នៅលើទាហរណ៍មិនល្អ។ លើកទឹកចិត្ត ដល់សិស្សឱ្យស្វែងរកឧទាហរណ៍ ស្ដីអំពីសិទ្ធិទាំងអស់។ ចូរក្រឡេកមើលនូវ*សេចក្ដីណែនាំគ្រូ* ហើយរយៈពេល ១០ នាទីក្រោយ អនុញ្ញាតឱ្យសិស្សពន្យល់ ដោយលើកឧទាហរណ៍របស់ពួកគេប្រាប់ទៅមិត្តរួមថ្នាក់។

លើកទឹកចិត្តដល់សិស្ស ដោយនិយាយថា អ្នកឯងគឺជាគ្រូរបស់ពួកគេ ដែលចង់ឱ្យពួកគេមានសិទ្ធិទាំងអស់នេះ។ ជួនកាលវាពិតជាមានលក្ខណៈពិបាកក្នុងការទៅរៀន ដោយសារតែក្រុមគ្រួសាររបស់អ្នកចង់ឱ្យអ្នកធ្វើការងារ ឬធ្វើអ្វីផ្សេងទៀត។ អ្នកតែងតែព្យាយាមស្វែងរកនូវដំណោះស្រាយមួយ ក៏ប៉ុន្តែប្រសិនបើវាពិបាកអ្នកត្រូវតែធ្វើការជាក្រុម។ ការពិភាក្សាជាក្រុម នឹងអាចផ្ដល់ឱ្យអ្នកនូវគំនិតជាច្រើន និងភាពរឹងមាំផងដែរ។ ដូចអ្វីដែលយើងបានគិតអំពីការធ្វើឱ្យប្រសើរឡើងសម្រាប់ស្រីយ៉ានៅក្នុងករណីសិក្សា យើងអាចគិតអំពីការរីកចម្រើនដែលអាចកើតមានសម្រាប់មនុស្សគ្រប់ៗគ្នា ចូរកុំភ្លេចវា គឺជាសិទ្ធិរបស់អ្នក។

# សេចក្តីណែនាំគ្រូ

● ប្រសិនបើវាមានលក្ខណៈពិបាក ដើម្បីប្រមូលកាសែត អ្នកអាចធ្វើការប្រើប្រាស់ធនធានដទៃៗ ទៀតដែលមានដូចជា បទពិសោធន៍ទាំងឡាយរបស់សិស្ស ឬក៏អ្នកអាចឱ្យពួកគេគិតអំពីស្ថានការណ៍ទាំងឡាយណាទាក់ទងនឹងសិទ្ធិកុមារ ដែលកើតមាននៅក្នុងប្រទេសកម្ពុជា។ សិស្សអាចសរសេរនូវស្ថានការណ៍ទាំងអស់នេះ ដោយសរសេរពីរឬបីពាក្យនៅលើ ក្រដាសមួយ និងគូររូបទឹកមុខសប្បាយ ឬក្រៀមក្រំនៅលើក្រដាសទាំងអស់នោះ។

● សម្រាប់ព័ត៌មានបន្ថែមស្តីអំពីសិទ្ធិកុមារអាចធ្វើការស្វែងរកតាមរយៈ

http://www.oxfam.org.uk/education/resources/rights/

http://www.vcao.org.kh/?page_id=144

● ឯកសារបំណិនជីវិត នៃការយល់ដឹងពីពលរដ្ឋ ផ្តល់នូវប្រវត្តិព័ត៌មានបន្ថែម និងអាចជ្រើសរើសមកប្រើប្រសិនបើជា អ្នកគិតថា នេះមានជាប់ទាក់ទងសម្រាប់សិស្សទាំងអស់គ្នា។



# គិតពីវា

## រឿងរ៉ាវរបស់ស្រីយ៉ា

សួស្តី ខ្ញុំឈ្មោះ ស្រីយ៉ា ។ ខ្ញុំមានអាយុ៥ឆ្នាំ ហើយខ្ញុំរស់នៅក្នុងខេត្តកណ្តាល ។ ខ្ញុំមានឪពុកម្តាយ ហើយនិងប្អូនប្រុសស្រីចំនួន៥នាក់ទៀត ។ ឪពុករបស់ខ្ញុំជាជាងសំណង់ នៅឯក្រុងភ្នំពេញ ហើយខ្ញុំក៏មិនបានជួបគាត់អស់រយៈពេលជាយូរមកហើយ ។ ចំណែកឯម្តាយរបស់ខ្ញុំលក់ស៊ុបមីនៅផ្សារ ។ ខ្ញុំចូលចិត្តការសិក្សាអំពីប្រទេសផ្សេងៗ និងភាសាអង់គ្លេស ។ សព្វថ្ងៃនេះ ខ្ញុំពិតជាមានអារម្មណ៍មិនសប្បាយចិត្តទេ ដោយសារតែខ្ញុំមិនបានទៅរៀនទៀត ។ ខ្ញុំធ្លាប់ទៅរៀននៅពេលព្រឹក ក៏ប៉ុន្តែ ឥឡូវនេះខ្ញុំត្រូវជួយការងារម្តាយរបស់ខ្ញុំ ដោយសារគាត់មិនអាចថែរក្សាប្អូនប្រុសស្រីរបស់ខ្ញុំបាន ព្រោះគាត់រវល់លក់នៅផ្សារ ។ គាត់សុំឱ្យខ្ញុំនៅផ្ទះ ដើម្បីថែរក្សាប្អូនប្រុសស្រីជំនួសគាត់ ។

ជាការពិត ខ្ញុំត្រូវតែស្តាប់បង្គាប់ម្តាយឪពុករបស់ខ្ញុំ ដោយសារតែពួកគាត់ខិតខំរកប្រាក់ដើម្បីចិញ្ចឹមកូនទាំងអស់គ្នា ។ ខ្ញុំមិនអាចទៅរៀនទៀតបានទេ ដូច្នេះហើយទើបខ្ញុំមានអារម្មណ៍មិនសប្បាយចិត្ត ។

**ចូរធ្វើការពិភាក្សាជាមួយនឹងសមាជិកក្រុមរបស់អ្នក :**



១. តើស្រីយ៉ាជួយធ្វើការងារម្តាយនាង មានផលប៉ះពាល់វិជ្ជមានអ្វីខ្លះ?

២. តើលទ្ធផលអវិជ្ជមាន នៃការស្នាក់នៅផ្ទះរបស់ស្រីយ៉ាមានអ្វីខ្លះ?

៣. តើអ្នកមានស្គាល់នរណាម្នាក់ទេដែលមានរឿងរ៉ាវដូច ស្រីយ៉ា?

៤. ដើម្បីធ្វើអោយស្ថានភាពរបស់នាងប្រសើរឡើង តើស្រីយ៉ាត្រូវធ្វើដូចម្តេចខ្លះ?

៥. ហេតុអ្វីការទៅសាលារៀន មានសារៈសំខាន់ម្ល៉េះ?

**ចូរធ្វើការអង្កេតដោយខ្លួនអ្នក :**

សួរទៅកាន់មិត្តរួមថ្នាក់ចំនួន១០នាក់ អំពីចម្លើយរបស់ពួកគេចំពោះសំណួរទាំងឡាយខាងក្រោម ។ ចូរចងចាំៈ ត្រូវតែលើកសំណួរថា 'ហេតុអ្វី' ដើម្បីឱ្យសិស្សបញ្ជាក់ឱ្យបានច្បាស់ នៅពេលដែលអ្នកមិនយល់ ។

សំណួរៈ តើអ្នកគិតថា កុមារមានអាយុប៉ុន្មានដែលល្អសម្រាប់ពួកគេដើម្បី :

- ទៅសាលារៀនដោយខ្លួនឯង?
- កាន់កាំបិតដ៏មុតស្រួច និងឧបករណ៍ដទៃ?
- ធ្វើដំណើរដោយខ្លួនឯង និងទិញរបស់របរអ្វីមួយពីទីកន្លែងដែលនៅជិត?
- ចម្អិនម្ហូបដោយខ្លួនឯង?
- មើលថែរក្សាប្អូនប្រុសស្រី?
- ធ្វើការងារដើម្បីរកលុយ?

# មេរៀនទី ៤: ការលេងកំសាន្ត

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)



📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- បាល់តូចមួយដើម្បីទុកសម្រាប់បោះ
- ឯកសារសម្រាប់សិស្សទី៤ដែលជាឧទាហរណ៍នៃការសម្ភាសន៍
- ផែនការជំនួញ ដែលត្រូវបានបង្កើតនៅក្នុងមេរៀនទី២

☼ **វត្ថុបំណង**

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- តាក់តែងសំណួរដើម្បីស្វែងរកព័ត៌មាន ស្តីអំពីអ្វីដែលប្រជាជនមកពីសហគមន៍ចូលចិត្តធ្វើ ឬក៏លេងកំសាន្តនៅពេលដែលពួកគេទំនេរ
- សម្ភាសប្រជាជនមួយចំនួន ដែលបានមកពីសហគមន៍ដោយខ្លួនរបស់ពួកគេផ្ទាល់
- ផ្លាស់ប្តូរយុទ្ធសាស្ត្រ ដោយពឹងផ្អែកទៅលើផែនការជំនួញ ដើម្បីរកនូវប្រាក់កម្រៃឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន
- ដោះស្រាយបញ្ហានៅក្នុងផែនការជំនួញរបស់ពួកគេ និងជំរុញសិស្សដទៃទៀត ដើម្បីសម្រេចបាននូវគោលដៅរបស់ពួកគេ

**ចំណងជើងមេរៀនទី ៤: ការលេងកម្សាន្ត** 🕑 ១៥ នាទី

**សកម្មភាពទី ១ សេចក្តីផ្តើមៈ ល្បែងបាល់**

✋ លោកគ្រូ អ្នកគ្រូ និងសិស្សឈរជារង្វង់។

រួចឱ្យសិស្សគ្រូបោះបាល់បន្តឱ្យគ្នាទៅវិញទៅមក។ នៅពេលដែលចាប់បាល់បាន ពួកគេត្រូវហៅឈ្មោះរបស់មនុស្សដែលបោះបាល់ឱ្យទៅពួកគេ។ គ្រូអាចធ្វើការផ្លាស់ប្តូរល្បែងនេះផងដែរ ប្រសិនបើវាមានលក្ខណៈងាយស្រួលពេក ដោយប្តូរជា ការមិនហៅឈ្មោះ ក៏ប៉ុន្តែអាចនិយាយពី បន្លែ ឬទីក្រុង។

ចូរសួរសិស្សទាំងអស់គ្នាថាតើពួកគេដឹងនូវល្បែងណាមួយ ដែលអាចលេងជាមួយបាល់បាន។ ប្រសិនបើពួកគេ អាចរកនឹកឃើញអនុញ្ញាតឱ្យពួកគេធ្វើការពន្យល់នូវល្បែងនោះ បន្ទាប់មកចាប់ផ្តើមលេងល្បែងនោះ។ ប្រសិនបើរកនឹកឃើញនូវល្បែងនោះ ចូរលេងល្បែងណាមួយម្តងទៀតដែលបានមកពីមេរៀនដទៃ។ រយៈពេល៥នាទីក្រោយមក ឱ្យសិស្សអង្គុយចុះ ហើយនិយាយថា អ្នកសប្បាយ ជាមួយនឹងល្បែងនេះណាស់។

តើនរណាគេដែលចូលចិត្តលេងល្បែងកំសាន្ត? អ្នកលេងល្បែងណាមួយ? ចូរធ្វើការបង្ហាញផងដែរនូវល្បែងដែលលេងលើកុំព្យូទ័រ។ តើអ្នកលេងនៅកន្លែងណា?

**សកម្មភាពទី២ សកម្មភាពចម្បង** ⌚ ៦០ នាទី

អនុញ្ញាតឱ្យសិស្ស គិតជាបុគ្គល រយៈពេលពីរបីនាទីអំពីសំណួរមួយចំនួន ៖ *ហេតុ អ្វីបានជាវាមានសារៈសំខាន់ដើម្បីលេង?* ពួកគេអាចបង្កើត *ផែនទីគំនិតមួយ* ដូចដែលបានបង្ហាញនៅក្នុងមេរៀនទី១។

ចូរដើរជុំវិញ ហើយជ្រើសរើសយកឧទាហរណ៍ដ៏ល្អ។ សរសើរសិស្សចំពោះ លទ្ធផលរបស់ពួកគេ។

សិស្សមួយចំនួន អាចធ្វើបទបង្ហាញនូវការស្វែងរកឃើញរបស់ពួកគេ ហើយពន្យល់នូវអ្វីដែលពួកគេគិតថា វាសំខាន់ ឬក៏អាចផ្ដល់ជាឧទាហរណ៍អំពីវា។ ឧទាហរណ៍ ប្រសិនបើជាអ្នកលេងអុក អ្នករៀនពីការគិត ទុកជាមុន។ ហើយប្រសិនបើអ្នកលេងបាល់វិញ អ្នកសង្កេតឃើញថា អ្នកត្រូវតែជាក្រុម បើមិនដូច្នោះទេ អ្នកនឹង ចាញ់។

ឱ្យសិស្សស្ដាប់គ្នាទៅវិញទៅមក ហើយបំពេញបន្ថែម នូវ *ផែនទីគំនិតរបស់ពួកគេ* នៅពេលពួកគេឮអ្វីមួយ ដែលគិតថា មានសារប្រយោជន៍ចំពោះផែនទីរបស់ពួកគេផងដែរ។

*ផែនទីគំនិត* អាចមានលក្ខណៈដូចខាងក្រោមនេះ៖




វាពិតជាមានសារៈសំខាន់ក្នុងការលេង សម្រាប់អ្នកទាំងអស់គ្នា មិនមែនត្រឹមតែកុមារទេ សិស្សានុសិស្ស និងឪពុកម្ដាយក៏សំខាន់ដែរ។ អ្នកត្រូវការរបស់របរមួយចំនួន ដើម្បីចាប់ផ្ដើមលេងបាន។ នៅក្នុងមេរៀនទី៣ យើង បានសិក្សាអំពីការបែងចែកការងារ និងពេលទំនេរ។

តើមាននរណាដឹងអំពីភាពខុសគ្នារវាងការងារ និងពលកម្មកុមារឬទេ?

សម្ភារផ្សេងៗទៀត ដែលអ្នកត្រូវការ គឺជា*សម្ភារដែលត្រូវលេងជាមួយ* ។ ទីលានកីឡាមួយ ប្រដាប់ប្រដាក្មេងលេងល្បែង ក្តារខៀន ឧបករណ៍ផ្សេងៗ មិត្តភក្តិ។ យើងនឹងធ្វើការរៀបចំនូវការស្រាវជ្រាវមួយ នៅក្នុងភូមិរបស់យើងស្តីអំពី៖

- តើក្នុងការលេងកម្សាន្ត ប្រជាជនត្រូវចំណាយពេលប៉ុន្មាន ?
- តើពួកគេចូលចិត្តលេងល្បែងអ្វី?
- តើពួកគេលេងនៅកន្លែងណា?
- តើពួកគេគិតថា ការសម្របសម្រួលមានគ្រប់គ្រាន់ទេនៅក្នុងភូមិ ដើម្បីលេងកម្សាន្ត?
- ដើម្បីលើកទឹកចិត្តដល់ការលេង តើអ្នកភូមិចូលចិត្តមើលអ្វីនៅក្នុងភូមិរបស់ពួកគេ?

ដើម្បីរៀបចំការស្រាវជ្រាវមួយដ៏ល្អ យើងត្រូវតែធ្វើជាមួយគ្នា បង្កើតគម្រោងមួយ។ ចូរប្រាប់សិស្ស ទាំងអស់គ្នាថា អ្នកចង់ឱ្យពួកគេបង្កើតជាក្រុម ដែលមានសមាជិក ៦នាក់ ដោយក្រុមនីមួយៗត្រូវមាន*សមាជិកទាំងពីរភេទ និងសិស្សដែលមកពីតំបន់ខុសៗគ្នា នៃទីក្រុង/សហគមន៍។*

◈ ហេតុអ្វីនេះគឺជាបញ្ហាសំខាន់?

ពួកគេនឹងសាកសួរអ្នកភូមិទាំងឡាយជាមួយគ ដើម្បីដឹងអំពីឥរិយាបថ និងការប៉ងប្រាថ្នាដែលមានភាពសប្បាយរីករាយ។

ចូរសរសេរនូវសេចក្តីណែនាំនៅលើក្តារខៀន។

- ធ្វើការសម្ភាសន៍ សម្រាប់ក្រុមអាយុដែលខុសៗគ្នា
- បែងចែកកិច្ចការនៅក្នុងក្រុមការងាររបស់អ្នកឱ្យបានច្បាស់លាស់
- នៅចុងបញ្ចប់នៃមេរៀននេះ ការសាកសួរក៏ត្រូវបានបញ្ចប់

ជាជម្រើស ប្រសិនបើសិស្សមិនយល់នូវអ្វីដែលអ្នកធ្វើ អ្នកអាចប្រើប្រាស់នូវឯកសារទី៤ សម្រាប់សិស្សធ្វើជាឧទាហរណ៍។ព្រមជាមួយគ្នានោះផងដែរអ្នកអាចដើរតួក្នុងការសម្តែងមួយក៏បាន ដោយមនុស្សម្នាក់ជាអ្នកសួរ ហើយម្នាក់ទៀតគឺជាអ្នកឆ្លើយ។ ប្រសិនបើ សិស្សមានលក្ខណៈ សមទៅនឹងសកម្មភាពទាំងអស់នោះហើយ អ្នកអាចរំលងចំណុចនេះបាន ហើយទុកឱ្យពួកគធ្វើការអនុវត្តន៍តែម្តងដោយពួកគេចាប់សាកសួរដោយខ្លួនឯង។

✋ នៅខណៈពេល ក្រុមនីមួយៗកំពុងតែចាប់ផ្តើមធ្វើការគិត អំពីការស្រាវជ្រាវរបស់ពួកគេ ចូរដើរជុំវិញក្រុមទាំងមូល និងពិនិត្យមើលថា តើក្រុមនីមួយៗបានបែងចែកការងាររវាងសមាជិកបានល្អដែរ ឬទេ។ តើពួកគេគ្រប់ៗគ្នាយល់អំពីអ្វីដែលត្រូវធ្វើដែរឬទេ? នៅពេលដែលស្ទើរតែគ្រប់ក្រុមទាំងអស់បានបញ្ចប់ អ្នកអាចឱ្យពួកគេអនុវត្តន៍នូវ សំណួររបស់ពួកគេ។

ប្រសិនបើសម្ភាសន៍បានបញ្ចប់ អ្នកអាចសាកល្បងជាមួយ។ ប្រសិនបើអ្នកចង់ អ្នកអាចផ្លាស់ប្តូរ ឬក៏យកលំនាំតាមសំណួររបស់ពួកគេ ប្រសិនបើជាចាំបាច់។ បន្ទាប់ពីពួកគេ បានបង្កើតនូវកំណែថ្មីចុងក្រោយរបស់ពួកគេរួចមកពួកគេអាចព្រីនវាចេញនៅក្នុងកុំព្យូទ័រ។ ប្រសិនបើមិនដូច្នោះទេ ពួកគេត្រូវតែសរសេរជាឯកសារហើយថតចម្លងដ៏ច្បាស់មួយដែលពួកគេអាចប្រើប្រាស់នៅក្នុងមេរៀនទី៥។

## សកម្មភាពទី៣ បញ្ចប់ៈ មតិរិះគន់ 🕑 ១៥ នាទី

ថ្ងៃនេះ សិស្សទាំងអស់គ្នាត្រូវពិនិត្យទៅលើដំណើរការសហគ្រាសរបស់ពួកគេ។ ពួកគេ ត្រូវការយកគម្រោងជំនួញ ហើយពិនិត្យមើល តើការងារណាមួយដែលត្រូវបានធ្វើរួច។

រាល់សមាជិកក្រុមទាំងអស់ ត្រូវតែប្រាប់ទៅកាន់ក្រុមនូវអ្វីដែលបានធ្វើរួច ហើយតើវាបានដំណើរការដោយរបៀបណា។ ប្រសិនបើជាការងារមិនទាន់បានសម្រេចនៅឡើយ សមាជិកដទៃទៀត គួរតែផ្តល់នូវគំនិតមួយចំនួនអំពីវិធី ដើម្បីបញ្ចប់នូវកិច្ចការនេះឱ្យបានលឿន និងល្អ តាមដែលអាចធ្វើទៅបាន។



✋ គ្រូធ្វើដំណើរទៅកាន់ក្រុមទាំងអស់ ហើយសួរពួកគេ តើចំនួនប្រាក់ប៉ុន្មានដែលបានទទួលពីសហគ្រាសរបស់ពួកគេ។ ចូរធ្វើការសរសើរចំពោះក្រុមទៅលើការខិតខំប្រឹងប្រែងរបស់ពួកគេ។

ប្រសិនបើអ្នកនៅសល់ពេល ចូរលេងល្បែងរូបចម្លាក់។ ឱ្យសិស្ស ១០នាក់រើសយកទីតាំងនៅក្នុងថ្នាក់រៀនដែលទាក់ទងទៅនឹងល្បែងខុសៗគ្នា។ ចំណែកឯសិស្សដទៃទៀត ធរង់ចាំនៅផ្នែកម្ខាងទៀត នៃបន្ទប់រហូតដល់រូបចម្លាក់ទាំងអស់ ស្ថិតនៅតាមទីកន្លែង។ បន្ទាប់ពីនោះមក ពួកគេធ្វើទស្សនកិច្ចនៅឯ "សារមន្ទីរ" ហើយ ស្វែងរកមើល នូវ*រូបចម្លាក់*មួយណាដែលល្បែងតំណាងឱ្យ។ ប្រសិនបើពួកគេដឹង ពួកគេអាចបង្កើតនូវរូប បដិមាមួយ ដែលធ្វើឱ្យដូចទៅនឹងល្បែងដដែល។

## សេចក្តីណែនាំគ្រូ

ប្រសិនបើភូមិមានចំងាយឆ្ងាយពេក ដើម្បីរៀបចំការស្រាវជ្រាវ សម្រាប់មេរៀនទី៥ វាជាការល្អដែលត្រូវប្រាប់សិស្សឱ្យសាកសួរព័ត៌មានអំពីទីតាំង បន្ទាប់ពីចេញពីរៀន។ នៅក្នុងករណីនោះ សិស្សម្នាក់ៗអាចជ្រើសរើសយកសមាជិកណាដែលល្អសមរម្យចំនួន ៥នាក់ ពីក្នុងសហគមន៍របស់ពួកគេ ហើយរៀបចំសាកសួរនូវព័ត៌មានមួយចំនួន។ នៅក្នុងមេរៀនទី៥ ពួកគេអាចចែករំលែកនូវលទ្ធផល ហើយធ្វើទស្សនកិច្ចសិក្សារបស់ពួកគេ នឹងត្រូវបានជំនួសដោយសកម្មភាពផ្សេងទៅវិញ។ សម្រាប់ព័ត៌មានបន្ថែម អាចមើលនូវសេចក្តីណែនាំគ្រូនៅក្នុង មេរៀនទី៥។

ច្បាប់ខាងក្រោមនេះត្រូវប្រើប្រាស់លើកុមារទាំងអស់ ដោយមិនគិតពីអាយុ ភេទ ជំនឿសាសនា ពិការភាព ឬប្រវត្តិគ្រួសារឡើយ*

# យើងមានសិទ្ធិ...



1. និយាយអ្វីដែលយើងគិតថាមានឥទ្ធិពលមកលើយើង។ មនុស្សគ្រប់គ្នាគួរស្តាប់ពួកយើង និងយកគំនិតរបស់ពួកយើងទៅធ្វើការពិចារណា។



2. មានឈ្មោះមួយ និងសញ្ជាតិមួយ
3. នៅពេលធ្វើការសម្រេចចិត្តអំពីកុមារណាម្នាក់ មនុស្សគ្រប់រូបគួរ ជ្រើសរើសឧត្តមប្រយោជន៍ដែលល្អបំផុតសម្រាប់កុមារម្នាក់នោះ។
4. បង្ហាញពីគំនិត មនសិការ និងជំនឿសាសនារបស់ពួកគេ។
5. ចូលរួមក្នុងការប្រជុំ និងការរៀបចំផ្សេងៗ។
6. មានភាពឯកជនដោយគ្មានការរំខាន។
7. ទទួលព័ត៌មានអំពីប្រធានបទផ្សេងៗ រួមបញ្ចូលទាំងអំពីខ្លួនរបស់ពួកយើង។
8. ទទួលបានការថែរក្សាទាំងផ្នែករាងកាយ និងសុខភាព។
9. ទៅសាលារៀន។
10. ដើម្បីមានកម្រិតជីវភាពដ៏ល្អមួយ។
11. លេង និងធ្វើសកម្មភាពកំសាន្តមួយចំនួន។
12. ទទួលបានបរិស្ថានបរិសុទ្ធ មានសុវត្ថិភាព និងសុខភាពល្អ។
13. កុមារពិការត្រូវទទួលបានការជួយជ្រោមជ្រែងឱ្យរស់នៅក្នុងជីវិតដ៏ពេញលេញ និងរស់រវើក ព្រមទាំងក្លាយជាមនុស្សឯករាជតាមតែអាចធ្វើបាន។
14. ទទួលបានការការពារពីគ្រួសាររបស់យើង និងការរំលោភបំពាន ឬការប្រមាថ។
15. ទទួលបានការការពារពីថ្នាំញៀនគ្រោះថ្នាក់ទាំងឡាយ។
16. មានការការពារប្រឆាំងនឹងទាសភាព ការចាប់បង្ខំ ឬការជួញដូរ។
17. ទទួលបានការការពារប្រឆាំងនឹងការងារដែលមានគ្រោះថ្នាក់ ឬការងារដែលមិនសមរម្យសម្រាប់អាយុរបស់យើង។
18. ទទួលបានការការពារនៅពេលមានសង្គ្រាម។
19. ការពារខ្លួនរបស់យើង ប្រសិនបើគេចោទប្រកាន់ថាយើងបានធ្វើបទល្មើសអ្វីមួយ។
20. ហើយចុងក្រោយ យើងមានសិទ្ធិទទួលបានសិទ្ធិទាំងនេះពីមនុស្សរស់នៅជុំវិញយើង ពីគ្រួសាររបស់យើង ពីមិត្តភក្តិរបស់យើង ពីរាជរដ្ឋាភិបាល និងសង្គម។









ដោយសេចក្តីស្មោះត្រង់ពិ,

សិស្សទាំងឡាយនៅក្នុងសាលានេះ

# មេរៀនទី ៥: កន្លែងរបស់ខ្ញុំ

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- បាល់តូចមួយដើម្បីទុកសម្រាប់បោះ
- សិស្សត្រូវនាំយកទៅជាមួយនូវការសម្ភាសន៍ និងក្រដាសរបស់ពួកគេ ដើម្បីទុកសម្រាប់កត់ត្រាចម្លើយទាំងឡាយ

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាចៈ

- ប្រមូលព័ត៌មានដោយប្រសិទ្ធភាព ដោយពឹងផ្អែកទៅលើការស្ទង់មតិ តាមរយៈការសម្ភាស
- ជំរុញប្រជាជន ដែលមកពីសហគមន៍របស់ពួកគេ ឱ្យបង្ហាញនូវឥរិយាបថត្រឹមត្រូវ
- ពន្យល់នូវប្រធានបទ និងគោលបំណងរបស់ពួកគេក្នុងការសម្ភាសអ្នកខាងក្រៅ

**ចំណងជើងមេរៀនទី ៥: កន្លែងរបស់ខ្ញុំ** 🕑 ២០ នាទី

**សកម្មភាពទី១ សេចក្ដីផ្ដើមៈ បើកបរសុវត្ថិភាព**

ថ្ងៃនេះ សិស្សនឹងបន្តការធ្វើទស្សនកិច្ចសិក្សា នៅភូមិមួយ ដើម្បីធ្វើការស្ទង់មតិរបស់ពួកគេ។ រំលឹក នាំសិស្សឱ្យមានការប្រុងប្រយ័ត្ន នៅពេលដែលពួកគេកំពុងបើកបរនៅលើផ្លូវ។ ពួកគេអាចបង្កើតជាដៃគូ ក៏ប៉ុន្តែមិនឱ្យ លើសពីពីរនាក់ទេ បើមិនដូច្នោះទេពួកគេប្រាកដជា ធ្វើឱ្យមានការភ័យខ្លាចដល់ប្រជាជន នៅក្នុងសហគមន៍។

នរណាអាចប្រាប់ខ្ញុំបានអំពីច្បាប់សុវត្ថិភាពតាមផ្លូវ ថាតើកន្លែងណាដែលយើងត្រូវយកចិត្តទុកដាក់?

គ្រូក៏នឹងធ្វើការបើកបរជុំវិញផងដែរ ដើម្បីពិនិត្យមើលថា តើសិស្សមានឥរិយាបថយ៉ាងដូចម្ដេចនៅតាមផ្លូវ និងជួយនៅពេលណាមានការចាំបាច់។ អ្នកត្រូវតែឱ្យលេខទូរស័ព្ទទៅសិស្ស ដូច្នេះពួកគេអាចទាក់ទងមកអ្នក នៅពេលដែលពួកគេមានបញ្ហា ឬក៏មានសំណួរមួយចំនួន។

ប្រសិនបើអ្នកមិនច្បាស់លាស់ ចំពោះសុវត្ថិភាពនៅក្នុងតំបន់ វាគឺជាគំនិតល្អមួយដែលស្នើសុំទៅឪពុកម្តាយ ឬក៏អ្នកគ្រប់គ្រង ដើម្បីធ្វើដំនើរទៅជាមួយសិស្ស។ ការបង្កើតលក្ខណៈជាដៃគូ វាគឺជាមធ្យោបាយមួយល្អផងដែរ។ ចូរផ្តល់ដំបូន្មានដល់ពួកគេ ឱ្យធ្វើការសម្ភាសប្រជាជនដែលនៅតាមផ្លូវ ហើយមិនត្រូវចូលទៅក្នុងផ្ទះរបស់ប្រជាជនឡើយ។

ចូរជូនដំណឹងនៅពេលវេលាចុងក្រោយ ដើម្បីត្រឡប់មកសាលាវិញជាមួយនឹងសិស្ស។ រហូតមកដល់ពេលនោះ សិស្សអាចសាកសួរមនុស្សបានច្រើន តាមដែលអាចធ្វើទៅបាន។

**សកម្មភាពទី២ សកម្មភាពចម្បង** ⌚ ៦០ នាទី

សិស្សស្រាវជ្រាវនៅក្នុងភូមិ ឬក៏សហគមន៍។



**សកម្មភាពទី៣ ចុងបញ្ចប់ៈ មតិរិះគន់** ⌚ ១០ នាទី

សិស្សទាំងអស់ វាយតម្លៃទៅលើបទពិសោធន៍ នៅក្នុងក្រុមរបស់ពួកគេ។ សមាជិកទាំងអស់ត្រូវតែចូលរួមដោយប្រើប្រាស់សំណួរដូចខាងក្រោម (ចូរសរសេរសំណួរទាំងអស់នេះ នៅលើក្តារខៀន)៖

- តើបានធ្វើការទំនាក់ទំនងជាមួយប្រជាជនប៉ុន្មាននាក់?
- ចំពោះការសាកសួររបស់អ្នក តើប្រជាជន មានប្រតិកម្មយ៉ាងដូច?
- ចំពោះការសួរនេះ តើអ្នករៀបចំបានល្អទេ?
- តើប្រជាជន យល់សំណួររបស់អ្នក ដែរឬទេ?
- តើអ្នកមានព័ត៌មានទាំងអស់ ដែលអ្នកត្រូវការដើម្បីយកមកធ្វើជារបាយការណ៍សម្រាប់លទ្ធផលរបស់អ្នកឬទេ?

បន្ទាប់ពីនោះមក ចូរប្រមូលរបាយការណ៍ដែលបានសរសេរទាំងអស់ និងប្រាប់សិស្សទាំងអស់គ្នាថាពួកគេនឹងត្រូវរាយការណ៍ទៅកាន់មិត្តរួមថ្នាក់ នៅក្នុងមេរៀនលើកក្រោយ។

## សេចក្តីណែនាំគ្រូ

ប្រសិនបើភូមិដែលត្រូវធ្វើទស្សនកិច្ចសិក្សានៅឆ្ងាយ ឬក៏មានហេតុផលផ្សេងៗទៀត ហើយអ្នកគិតថាសិស្សមិនគួរទៅក្រៅសាលា អ្នកអាចធ្វើការជ្រើសរើស ដើម្បីផ្លាស់ប្តូរមេរៀននេះបាន។

នៅក្នុងមេរៀនទី៤ សិស្សទាំងអស់គ្នា បានរៀបចំការស្រាវជ្រាវ របស់ពួកគេជាកិច្ចការផ្ទះ។ ព័ត៌មាននេះត្រូវបានចែករំលែកនៅក្នុងក្រុមស្រាវជ្រាវរបស់ពួកគេ។ បន្ទាប់ពីចែករំលែកនូវបទពិសោធន៍របស់ពួកគេ ចូរ ប្រើប្រាស់សកម្មភាពទី៣ ពីមេរៀនសំខាន់ៗ ហើយចាប់ផ្តើមវិភាគសម្ភារៈរបស់ពួកគេ ដោយការប្រើប្រាស់មេរៀនទី៦ ។

ជម្រើសមួយទៀត គឺត្រូវរៀបចំការសម្ភាស ជាមួយសិស្សដែលមកពីក្រុមដទៃទៀត។ ធ្វើដូច្នេះយើងនឹងអាចសន្សំសំចៃពេលវេលាបានច្រើន ហើយក៏អាចផ្តល់នូវលទ្ធផលល្អផងដែរ។

# មេរៀនទី ៦: គួរធ្វើ និងមិនគួរធ្វើ

រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

សម្ភារឧបទេស ធនធានដែលត្រូវការ

- បាល់តូចមួយដើម្បីទុកសម្រាប់បោះ
- ក្រដាសសម្រាប់បិទភ្ជាប់គ្នាចំនួនមួយ ឱ្យទៅកាន់ក្រុមនីមួយៗ
- ឯកសារទី៦ សម្រាប់សិស្សមួយឈុត សម្រាប់ក្រុមនីមួយៗ

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- រៀបចំព័ត៌មានរបស់ពួកគេ នៅក្នុងមធ្យោបាយដែលមានរចនាសម្ព័ន្ធមួយ ហើយនិងស្វែងរកនូវសេចក្តីសន្និដ្ឋានទាំងឡាយ
- ផ្តល់អាទិភាពចំពោះលទ្ធផលដែលទទួលបាន ដោយផ្អែកទៅលើការពិភាក្សារវែកញែក
- ធ្វើបទបង្ហាញនូវដំបូន្មានរបស់ពួកគេទៅកាន់ "ប្រធាន" ឱ្យបានច្បាស់ និងដោយការសង្ខេបខ្លីៗ។

**ចំណាងជើងមេរៀនទី ៦ៈ គួរធ្វើ និងមិនធ្វើ** ៤០ នាទី

**សកម្មភាពទី១ សេចក្តីផ្តើមៈ ប្រធាន**

ថ្ងៃនេះ អ្នកធ្វើជាប្រធានសហគមន៍ សិស្សទាំងអស់គ្នាបានចុះស្រាវជ្រាវ ហើយអ្នកគឺជាមនុស្សដែលចង់ទទួលដំណឹងពីពួកគេ ដោយសារតែអ្នកគិតថា ការលេងគឺពិតជាសំខាន់ក្នុងការអភិវឌ្ឍន៍ខ្លួនឯង ក៏ដូចជាសុជីវធម៌ផងដែរ។ នៅពេលដែលមនុស្សមានអារម្មណ៍ធុញថប់ពួកគេក៏មានការមិនពេញចិត្តចំពោះការងារ ហើយចំពោះអ្នកវិញគឺចង់ឃើញមនុស្ស សប្បាយចិត្តរីករាយជាមួយនឹងខ្លួនរបស់ពួកគេផ្ទាល់។ ដូច្នេះអ្នកត្រូវការដំបូន្មានពីសិស្សានសិស្សទាំងអស់គ្នា។ សិស្សទាំងអស់គ្នា នឹងប្រៀបធៀបលទ្ធផលរបស់ពួកគេ នៅក្នុងក្រុម ហើយនឹងបង្កើតសេចក្តីសន្និដ្ឋានមួយ។

បន្ទាប់ពីនេះ ពួកគេនឹងសរសេរ ការស្នើសុំមួយច្បាប់សម្រាប់ "លោកប្រធាន" ហើយធ្វើបទបង្ហាញទៅកាន់គាត់ ក៏ដូចជាមិត្តរួមថ្នាក់ទាំងអស់គ្នា។

លោកប្រធានចង់បានសិស្សពូកែ១០នាក់ ដែលបានផ្តល់អាទិភាពទៅលើសារៈសំខាន់

ចូរផ្តល់ឯកសារទី៦ សម្រាប់សិស្ស

| អាយុ | សប្បាយរីករាយជាមួយនឹង | ត្រូវការសម្រាប់ | ភាពខុសគ្នា | ភាពដូចគ្នា | ដំបូន្មាន | អាទិភាព |
|---|---|---|---|---|---|---|
| កំណត់ *លំដាប់* ឧ. ០-៤ ឆ្នាំ ៤-៨ ឆ្នាំ ។ល។ | សរសេរចូលនូវអ្វីមួយដែលជាកន្លែងមនុស្ស *ពេញចិត្ត* | របស់ដែលមានរួចហើយមួយណាដែលពួកគេចង់ធ្វើ *ការផ្លាស់ប្តូរ* និងរបស់ថ្មីមួយណាដែលពួកគេចង់ធ្វើឱ្យរីកចម្រើន | កត់ចំណាំនូវលក្ខណៈខុសគ្នារវាង *អាយុ* និង *ភេទ* | តើរបស់អ្វីច្រើនជាងគេដែលសមាជិកក្រុមចូលចិត្តមើល ? | បង្កើតនូវ *ទម្រង់រូបមន្ត* ដំបូន្មានដ៏ជាក់លាក់មួយចំពោះលោកប្រធាន | ដោយពឹងផ្អែកទៅលើចម្លើយដែលផ្តល់ដោយប្រជាជនដាក់ដំបូន្មានតាមប្រភេទតាមលំដាប់នៃ *សារ សំខាន់* |

ចូរពន្យល់ខ្លឹមសារនៃឯកសារសម្រាប់សិស្ស ដោយប្រើប្រាស់ឧទាហរណ៍សម្រាប់ប្រភេទនីមួយៗ។ សិស្សត្រូវធ្វើការងារជាក្រុមដែលមានគ្នា៥/៦នាក់ក្នុងមួយក្រុម។ អ្នកអាចសម្រេចបានថា តើពួកគេចង់បង្កើតក្រុមដោយខ្លួនឯង ឬក៏អ្នកចង់ធ្វើវាដោយខ្លួនអ្នកផ្ទាល់។ ចំពោះកំណែចុងក្រោយនៃតារាង/កាលវិភាគរបស់ពួកគេ អាចត្រូវបានសរសេរចូលនៅលើ ក្រដាសដែលបិទភ្ជាប់គ្នា។

នៅខណៈពេលដែលសិស្សកំពុងតែធ្វើការងារ និងកំពុងតែធ្វើការពិភាក្សាគ្នាអំពីលទ្ធផលរបស់ពួកគេ វាជាការល្អដើម្បីធ្វើការត្រួតពិនិត្យមើល តើអ្នកទាំងអស់ចូលរួមក្នុងការពិភាក្សាឬទេ។ ប្រសិនបើមិនដូច្នោះទេ អ្នកអាចធ្វើវាឱ្យកាន់តែមានភាពរស់រវើក ដោយធ្វើការភ្ជាប់គ្នានូវការសង្ខេបរបស់ក្រុម និងសួរ៖ តើអ្វីដែលជាលទ្ធផលរបស់អ្នកចំពោះសំណួរនេះ ?

ចូរប្រយ័ត្ន៖ នេះគឺជាពេលវេលាល្អ សម្រាប់គ្រូក្នុងការបំពេញនៅក្នុង *តារាងវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ*។ ជាពិសេសយកចិត្តទុកដាក់ទៅលើការគិតស៊ីជម្រៅ ការសហការ អាកប្បកិរិយាវិជ្ជមាន និងការសម្រេចចិត្ត។

សិស្សទាំងអស់គ្នា នឹងត្រូវស្វែងរកនូវមធ្យោបាយណាដែលទាក់ទាញអារម្មណ៍ ដើម្បីធ្វើបទបង្ហាញអំពីលទ្ធផលរបស់ពួកគេ។ នៅលើក្រដាសកិច្ចការ ពួកគេត្រូវបានស្នើសុំឱ្យគិតអំពីលទ្ធផលនោះផងដែរ។ ប្រហែលជាអ្នកអាចផ្តល់ដីសឱ្យពួកគេដើម្បីសរសេរនៅលើក្តារខៀន ឬក៏ក្រដាសដែលពួកគេអាចសរសេរ ដើម្បីបង្ហាញនូវដំបូន្មានរបស់ពួកគេ។

**សកម្មភាពទី២ សកម្មភាពចម្បង** ⌚ ៤០ នាទី

គ្រូនឹងអញ្ជើញគ្រប់ក្រុមទាំងអស់ឱ្យមកធ្វើបទបង្ហាញនូវគំនិតរបស់ពួកគេ ដោយក្រុម នីមួយៗមានរយៈពេល៥នាទី។

ចំពោះមតិរិះគន់ អាចត្រូវបានផ្តល់ឱ្យសិស្សទាំងអស់គ្នា ដោយគ្រូ ឬក៏សិស្សដទៃទៀត។ ចូរចងចាំក្នុងការប្រើប្រាស់ពាក្យថាល្អ និងធ្វើឱ្យប្រសើរសម្រាប់អ្វីដែលអាចធ្វើឱ្យប្រសើរឡើង។ ខាងក្រោមនេះគឺជាអ្វីៗអាចត្រូវបានធ្វើការវាស់ស្ទង់ ៖

- តើអ្នកទាំងអស់គ្នាមានបានចូលរួមទេ?
- តើសិស្សនិយាយចេញមក ឮច្បាស់គ្រប់គ្រាន់ទេ?
- តើពួកគេឈរបានត្រង់ល្អ ហើយគ្រប់ៗគ្នាអាចមើលឃើញពួកគេទេ ?
- តើការធ្វើបទបង្ហាញរបស់ពួកគេកាន់តែមានភាពល្អប្រសើរ ឬក៏មិនសូវល្អ?

កុំធ្វើការរិះគន់ខ្លាំងពេក ដោយសារតែពួកគេមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំទេ។

**សកម្មភាពទី៣ ចុងបញ្ចប់ៈ (ជម្រើស)** ១០ នាទី

អ្នកអាចឱ្យសិស្សគ្រប់គ្នាៗនូវតួអក្សរមួយ។ ពួកគេត្រូវតែធ្វើការរំឭកអំពីវា និងហៅវាចេញនៅពេលដែលល្បែងចាប់ផ្តើម។ រាល់សិស្សទាំងអស់គ្នាទទួលបាន នូវតួអក្សរខុសៗគ្នា។ ចំពោះ លំហាត់ គឺត្រូវឱ្យសិស្សបញ្ចូលគ្នានូវតួអក្សរទាំងអស់ឱ្យទៅជាពាក្យ។ សិស្សដែលមានតួអក្សរ ស អាចបង្កើតជាពាក្យមួយ ដែលមានតួអក្សរ ហ និង គ នៅ ជាមួយ។ នេះអាចត្រូវបានលេងជាច្រើនដង ដើម្បីបង្កើតនូវពាក្យខុសៗគ្នា។

## សេចក្តីណែនាំគ្រូ

វាអាចមានប្រយោជន៍ និងសប្បាយដែលអញ្ជើញប្រជាជនមកពីសហគមន៍ ឱ្យចូលរួមក្នុងការធ្វើបទបង្ហាញរបស់កុមារ។ ប្រហែលប្រធានសហគមន៍ អាចមានពេលវេលាមកចូលរួមផងដែរ។ ចូរពន្យល់ថា នេះគឺជាលំហាត់មួយដែលមិនចាំបាច់ត្រូវធ្វើការឆ្លុះបញ្ចាំង នូវគំនិតរបស់ប្រជាជន។ ប្រសិនជាលោកប្រធានអាចមកចូលរួមបាន ចូររៀបចំសិស្សនៅក្នុងការបង្ហាញ សម្រាប់ព្រឹត្តិការណ៍នេះ។



# គិតពីវា

តើដំណើរការសួរសំនួរប្រព្រឹត្តទៅដូចម្តេចដែរ? តើអ្នកគឺជាអ្នកធ្វើការអង្កេតដ៏ល្អមួយ រូបឬ? ឥឡូវនេះ យើងនឹងប្រមូលផ្តុំនូវព័ត៌មានក្នុងក្រុមរបស់យើង ហើយយើង នឹងពិភាក្សាគ្នា ហើយធ្វើសេចក្តីសន្និដ្ឋានមានសារៈសំខាន់មួយចំនួន ។ ដំបូង ចូរស្តាប់គ្រូ ។ គាត់នឹងពន្យល់ពីផ្នែកខុសៗគ្នាជាច្រើន ។ បន្ទាប់ពីនោះមក យើងនឹងអនុវត្តន៍តាមជំហានទាំងឡាយខាងក្រោម។



១.សមាជិកទាំងអស់របស់ក្រុម នឹងប្រាប់នូវអ្វីដែលជាលទ្ធផល របស់ពួកគេ ។

២.គ្រប់ៗគ្នាត្រូវស្តាប់ពីរបៀបសាកសួរ របស់ពួកគេ ។

៣. បន្ទាប់មក យើងបំពេញតាមផ្នែកខុសៗគ្នាដែល មាននៅក្នុងតារាង។

ចូរចងចាំ : តែងតែធ្វើការសាកសួរ ថាតើពួកយើងទាំងអស់គ្នាយល់ព្រមតាមសេចក្តីសន្និដ្ឋាន និងដំបូន្មានរបស់យើងឬទេ ។

យើគិតខុសៗត្រូវបើកចិត្តរបស់អ្នកឱ្យទទួលយកគំនិតថ្មីៗជាច្រើន!

បន្ទាប់ពីនេះ យើងត្រូវគិតពីមធ្យោបាយក្នុងការធ្វើបទបង្ហាញពីលទ្ធផលរបស់យើង ទៅកាន់មិត្តរួមថ្នាក់ទាំងអស់គ្នា ។ យើងក៏ត្រូវធ្វើឱ្យ 'លោកប្រធានសហគមន៍' មានទំនុកចិត្តផងដែរថារាល់ដំបូន្មានរបស់ពួកយើង គឺសុទ្ធតែមានសារៈសំខាន់ ។

តើយើងអាចធ្វើដូច្នោះបានដោយរបៀបណា?

ប្រហែលជាយើងអាចប្រើប្រាស់នូវឧទាហរណ៍ល្អៗទាំងឡាយ ឬក៏យើងអាចប្រើសម្ភារៈមួយចំនួនដើម្បីពន្យល់ពីអ្វីដែលយើងចង់បង្ហាញប្រាប់។ តើយើងគួរតែសរសេរដំបូន្មានរបស់យើងនៅលើក្តារខៀនដីសឬទេ? ធ្វើដូច្នេះមនុស្សម្នាទាំងអស់គ្នាអាចចងចាំបានល្អប្រសើរ?

សំខាន់ផងដែរ: សមាជិកទាំងអស់នៃក្រុមរបស់យើងត្រូវតែចូលរួមនៅក្នុងការធ្វើបទបង្ហាញ ។ តើយើងនឹងបែងចែកដោយវិធីណា?





| អាយុ | សប្បាយជាមួយ | ត្រូវការសម្រាប់ | ភាពខុសគ្នា | ភាពដូចគ្នា | ជំហានបន្ទាន | អាទិភាព |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

# មេរៀនទី ៧: ការសម្រេចចិត្ត

🕑 រយៈពេលបង្រៀន: ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាសតូចមួយសម្រាប់សិស្សគ្រប់គ្នា ជាសន្លឹកឆ្នោត និងប្រអប់(ក្រដាស) គឺត្រូវបានប្រើប្រាស់ជាប្រអប់ឆ្នោត

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ប្រាប់គោលការណ៍ និងហេតុផលនៃការបោះឆ្នោត
- វាយតម្លៃទៅលើការប្រឹងប្រែងរបស់ពួកគេ និងអ្នកដទៃ ព្រមជាមួយសញ្ញាល្អនិងការធ្វើឱ្យកាន់តែប្រសើរឡើង
- អង្កេតទៅលើព្រឹត្តិការណ៍ដែលអាចកើតមានឡើងបាន ដោយពឹងផ្អែកទៅលើពេលទំនេរនិងលុយដែលរកបាន

**ចំណងជើងមេរៀនទី ៧: ការសម្រេចចិត្ត** 🕑 ៤០ នាទី

**សកម្មភាពទី១ សេចក្តីផ្តើម**

ថ្ងៃនេះ យើងចាប់ផ្តើមសរសេរការវាយតម្លៃ សកម្មភាពរបស់ពួកគេផ្ទាល់ ដោយពឹងផ្អែកទៅ លើគម្រោងជំនួញ។ ចូរគិត និងបែងចែកវាជាពីរក្រុម គឺ *ល្អ* និង *ការធ្វើឱ្យកាន់តែប្រសើរឡើង*។ បន្ទាប់ពីនោះមក សមាជិកទាំងអស់របស់ក្រុម ធ្វើដំណើរទៅសហគ្រាសរបស់ពួកគេ និងជម្រាបនូវអ្វីគ្រប់យ៉ាងដែលពួកគេបានសរសេរ។ គ្រប់ៗគ្នាស្តាប់នូវការបង្ហាញទាំងអស់នោះ។ នៅពេលដែលសមាជិកទាំងអស់ បានវាយតម្លៃទៅលើការបង្ហាញរបស់ពួកគេរួច វាគឺជាពេលដែលត្រូវផ្តល់ *មតិយោបល់* និង *កោតសរសើរ* ។

នៅពេលដែលអ្នកបានពិភាក្សាជាមួយនឹងមនុស្សដទៃ វាពិតជាសំខាន់ណាស់ ដើម្បីផ្តល់ នូវបរិយាកាសវិជ្ជមាន។ មានច្បាប់សំខាន់មួយចំនួនសម្រាប់ដោះស្រាយបញ្ហាទាំងអស់នោះ។

សរសេរនូវវិន័យសំខាន់ៗ ដែលបានគូសបន្ទាត់ពីក្រោម នៅលើក្តារខៀន

- ជ្រើសរើសអ្នកដឹកនាំមួយដែលអាចបញ្ឈប់ការពិភាក្សាដ៏វែង ឬក៏ធ្វើការ សម្រេចចិត្តដែលអ្នកគ្រប់គ្នាត្រូវតែធ្វើតាម។ អ្នកដឹកនាំនេះត្រូវពិនិត្យមើលពេលវេលា និងត្រូវប្រាកដប្រជាថា រាល់សមាជិកទាំងអស់មានឱកាសក្នុងការនិយាយ។

- ត្រូវមានភាពគួរសមក្នុងការប្រើប្រាស់ភាសា និងអាកប្បកិរិយារបស់អ្នក
- កុំកាត់សំដី អ្នកដែលកំពុងនិយាយ
- ស្វែងរកនូវតុល្យភាព រវាង ការផ្តល់មតិយោបល់ និងការកោតសរសើរ

ពួកយើងបានបង្កើតសហគ្រាសនេះជាក្រុម ឥឡូវនេះយើងវាយតម្លៃជាក្រុម។ ចូរប្រាប់សមាជិកដទៃទៀតរបស់ក្រុមអំពីអ្វីដែលពួកគេធ្វើបានល្អ(សរសើរ) និងអ្វីដែលពួកគេអាចធ្វើឱ្យរីកចម្រើន(មតិយោបល់)។ អ្នក មានរយៈពេល១០នាទីក្នុងការធ្វើ ការជាក្រុម ដូច្នេះជាដំបូង ចូរជ្រើសរើសអ្នកដឹកនាំម្នាក់ដែលចាំផ្ទៀងម៉ោង និង ធ្វើប្រាកដប្រជាផងដែរថា គ្រប់ៗគ្នាធ្វើតាមច្បាប់សំខាន់ទាំងអស់នោះ។

ចូរដើរជុំវិញ និងពិនិត្យមើល ថាតើសមាជិកទាំងអស់ចូលរួមពិភាក្សាបានល្អឬក៏អត់។ ចូរចងចាំៈ ថានេះជាឱកាសក្នុងការត្រួតពិនិត្យ*ភាពរាងវាយតម្លៃរបស់សិស្សម្នាក់ៗ*ទៅ លើប្រធានបទ *ការសហការ ការទំនាក់ទំនង ការយល់ចិត្ត* និង *ការជឿជាក់ទៅលើខ្លួនឯង*។

ស្នើសុំមតិរិះគន់។ ឧទាហរណ៍ៈ តើអ្នកអាចនិយាយអ្វីដែលមាននៅក្នុងចិត្តរបស់អ្នកបានដែរឬទេ? តើអ្នកទទួលបាននូវមតិយោបល់ ជាការសរសើរមួយចំនួនដែរឬទេ? ហេតុអ្វីបាន ជាយើងគួរតែសរសើរហើយមិនផ្តល់ជាមតិយោបល់? តើអ្នកទាំងអស់គ្នាទទួលបានឱកាសក្នុងការនិយាយដែរឬទេ? នៅចុងបញ្ចប់ គ្រូកោតសរសើរសិស្សចំពោះការងាររបស់ពួកគេ ទោះបីជាក្រុមទាំងអស់រកមិនបាននូវប្រាក់កម្រៃច្រើនក៏ដោយ ហើយពួកគេនៅតែមាន គម្រោងល្អៗដោយបែងចែករវាងការងារ និងការធ្វើការជាមួយគ្នា។(ជម្រើស)លេងល្បែង"នរណាជាអ្នកដឹកនាំ?" ស្នើសុំអ្នកស្ម័គ្រចិត្តម្នាក់ឱ្យចាកចេញពីបន្ទប់។ ចំណែកក្រុមដែលនៅសល់គឺត្រូវនាំគ្នាឈរជារង្វង់ ហើយជ្រើសរើសនរណាម្នាក់ឱ្យធ្វើជាអ្នកដឹកនាំ។ អ្នកដឹកនាំត្រូវធ្វើចលនាផ្លាស់ប្តូរយឺតៗ ដែលសមាជិកដទៃទៀតត្រូវធ្វើតាមសកម្មភាពទាំងអស់នោះ។

ឱ្យអ្នកស្ម័គ្រចិត្តចូលមកក្នុងបន្ទប់វិញ នៅពេលដែលអ្នកដទៃទៀត កំពុងតែធ្វើត្រាប់តាមអ្នកដឹកនាំ និងនាំគ្នាឈរជារង្វង់។ អ្នកស្ម័គ្រចិត្តមានឱកាស ៣ដង ដើម្បីប្រាប់ថានរណាជាអ្នកដឹកនាំ។ វាពិតជាសំខាន់ណាស់ ត្រូវរំលឹកដល់ក្រុមមិនឱ្យក្រឡេកមើលអ្នកដឹកនាំដាច់ខាត ដោយសារសកម្មភាពនេះ អាចបង្ហាញនូវអត្តសញ្ញាណរបស់គាត់។

## សកម្មភាពទី២ ថ្ងៃសម្រេចចិត្ត ⌚ ៤០ នាទី

ក្រុមនីមួយៗ មានសៀវភៅកត់ត្រាលុយមួយក្បាល ហើយពួកយើងក៏ដឹងផងដែរនូវចំនួនលុយដែលរកបាន។ នេះនឹងក្លាយជាថវិការបស់យើងសម្រាប់បង្កើតព្រឹត្តិការណ៍របស់សហគមន៍ នាពេលខាងមុខនេះ។ ដោយពឹងផ្អែកទៅលើ ចំនួនប្រាក់ប៉ុន្មានដែលយើងមានយើងត្រូវតែធ្វើការសម្រេចចិត្តថា អ្វីដែលអាចកើតមាន។ នេះក៏ពឹងផ្អែកទៅលើគោលដៅរបស់ក្រុមផងដែរ មានជម្រើសចំនួនបី។

✎ ចំណូលសរុប គឺត្រូវបានសរសេរនៅលើក្តារខៀន។ ស្នើសុំឱ្យសមាជិកម្នាក់ៗនៃក្រុមនីមួយៗ ធ្វើវា។ នៅចន្លោះពេលនោះផងដែរ សរសេរនូវជម្រើសទាំងបីខាងក្រោម។

| | |
|---|---|
| មិនមានលុយច្រើន | រៀបចំនូវព្រឹត្តិការណ៍សម្រាប់ក្រុមតូចមួយ |
| | រៀបចំនូវព្រឹត្តិការណ៍ណាមួយដែលមិនចំណាយលុយច្រើនសម្រាប់ក្រុមធំមួយ |
| មានលុយច្រើន | រៀបចំនូវព្រឹត្តិការណ៍សម្រាប់ក្រុមធំមួយ |

សួរសំណួរ ៖ តើក្រុមមួយណាដែលយើងអាចអញ្ជើញ?
ឧទាហរណ៍ ៖ វ័យចំណាស់ ក្មេងតូចៗ គ្រួសាររបស់យើង សាលារៀន អ្នកភូមិទាំងមូល...

វាអាស្រ័យទៅលើសិស្សទាំងអស់គ្នា សម្រេចចិត្តនូវអ្វីដែលពួកគេចង់ធ្វើជាមួយនឹង លុយរបស់ពួកគេ។ រាល់ការសម្រេចចិត្តនីមួយៗគឺចេញមកពីពួកគេ។ ត្រឹមតែល័ក្ខខ័ណ្ឌមួយ ប៉ុណ្ណោះទេដែលមានដោយគ្រាន់តែសម្រាប់ព្រឹត្តិការណ៍មិនមែនសម្រាប់តែពួកគេទេ ក៏ប៉ុន្តែ ជាផ្នែកមួយរបស់សហគមន៍ផងដែរ។ អ្នកអាចសម្រេចចិត្តដើម្បីប្រើប្រាស់ការស្ទង់មើលដែលបានមកពីមេរៀនទី៥ នៅក្នុងម៉ូឌុល នេះ។ តើរបស់មួយណាដែលអ្នកភូមិបាននឹក ឃើញ ហើយតើពួកយើងអាចធ្វើការប្រើប្រាស់ នូវគំនិតរបស់ពួកគេដើម្បីរៀបចំនូវអ្វីមួយដោយរបៀបណា។ ចូរទុក ពេលឲ្យសិស្សពីរ ឬបីនាទីដើម្បីគិតអំពីជម្រើសសម្រាប់ព្រឹត្តិការណ៍មួយ។

ប្រសិនបើអ្នកគិត ឬក៏ស្វែងរកឃើញថា សិស្សទាំងអស់ត្រូវការគំនិតមួយចំនួនដើម្បីយល់ នូវការងារ អ្នកអាចប្រើប្រាស់បញ្ជី សកម្មភាពទាំងឡាយនៅក្នុង *សេចក្តីណែនាំគ្រូ*។

នៅពេលដែលជម្រើសទាំងអស់ត្រូវបានសរសេរ គ្រូអាចជួយជំរុញការត្រិះរិះរកគំនិតថ្មីរបស់ពួក គេដោយធ្វើការដាក់ពណ៌ចំណាំនៅលើពាក្យមួយចំនួនខាងក្រោមនៅលើក្តារខៀន។

✎ (ក្រុមដែលត្រូវបានជ្រើសរើស) តន្ត្រី ល្បែង កីឡា រាំ អាហារ ការកំសាន្ត ជួយ

សិស្សទាំងអស់បង្កើតជាក្រុមដែលមានគ្នា៣នាក់ និងចាប់ផ្តើមរិះរកនូវគំនិតមួយចំនួន អំពីព្រឹត្តិការណ៍មួយដែលអាចកើតមាន។ ពួកគេមិនត្រូវគិតអំពីការរៀបចំ ថាតើវានឹងត្រូវចំណាយ ដោយរបៀបណាទេ។ គ្រាន់តែប្រាប់ពួកគេថា យើងត្រូវការតែគំនិតមួយចំនួនតែប៉ុណ្ណោះ។ រាល់ជម្រើសទាំងអស់គឺត្រូវបានសរសេរនៅលើក្រដាសមួយ ក៏ប៉ុន្តែរយៈពេល៥នាទីក្រោយ អ្នកប្រាប់មនុស្សម្នាក់ដែលមកពីក្រុមនីមួយៗឱ្យប្តូរទៅកាន់ក្រុមដទៃទៀត និងនៅតែបន្តធ្វើការនឹករកនូវគំនិតមួយចំនួនដដែល។ ឥឡូវ ក្រុមទាំងអស់ត្រូវបានបញ្ចូលគ្នា ហើយការគិតក៏កាន់តែមានភាពរស់រវើក។ ការពិតពួកគេគួរពិនិត្យជាមុនសិន ថាតើគំនិតរបស់ពួកគេមិនទាន់ត្រូវបានសរសេរដោយក្រុមដទៃ។ នៅទីបំផុត យើងនឹងមានបញ្ជីមួយដែលមានជម្រើសជាច្រើន។

ចូរចាប់ផ្តើមការពិភាក្សាជាក្រុម ដែលស្តីអំពីជម្រើសណាមួយដែលមិនអាចទៅរួច។ ចូរគិតអំពីៈ

- តើវាអាចទៅរួចទេដើម្បីរៀបចំ ក្នុងរយៈពេលត្រឹមតែពីរសប្តាហ៍?
- តើយើងមានលុយគ្រប់គ្រាន់ទេ ដើម្បីចំណាយទៅលើអ្វីដែលយើងត្រូវការ? នៅពេលដែលសិស្ស និងគ្រូ

យល់ព្រម សកម្មភាពដែលនៅសល់ គួរតែអាចធ្វើបាន ហើយវាក៏ជាពេលដែលត្រូវបោះឆ្នោតផងដែរ។ ដោយសារតែបុគ្គលម្នាក់ៗមានគំនិតផ្ទាល់ខ្លួនរបស់គេចំពោះប្រធានបទជាច្រើនជារឿយៗវាមិនអាចយល់ព្រមបានទេទៅលើអ្វីដែលខុសគ្នា។ ដូច្នេះមនុស្សទាំងអស់គ្នាមានប្រព័ន្ធបោះឆ្នោត។ មានច្បាប់សំខាន់ៗចំនួន ៣ សម្រាប់ការបោះឆ្នោត។

- វាអាចគ្មានឈ្មោះ
- គ្រប់ៗគ្នា ធ្វើការជ្រើសរើសសម្រាប់ខ្លួនឯង
- ការសម្រេចចិត្តចុងក្រោយត្រូវតែជ្រើសរើស ដោយយោងទៅតាមមតិភាគច្រើននៃអ្នកបោះឆ្នោត

## សកម្មភាពទី៣ ការបោះឆ្នោត

🕑 ១០ នាទី

ចូរឱ្យសិស្សទាំងអស់គ្នានូវសន្លឹកឆ្នោតមួយសន្លឹកម្នាក់ និងឱ្យពួកគេសរសេរ នូវចំណុចសំខាន់ចំនួន៣ដែលពួកគេចង់ធ្វើបំផុត។ ចូរចងចាំថា នេះជាការជ្រើសរើសសម្រាប់ខ្លួនរបស់អ្នក! មធ្យោបាយដែលល្អបំផុត គឺត្រូវរក្សាការសំងាត់។

ក្រោយមក សិស្សប្រុសនិងស្រី ពីរៗនាក់ ត្រូវបានជ្រើសរើសឱ្យរាប់ សន្លឹកឆ្នោត។

ប្រព័ន្ធនៃការរាប់សន្លឹកឆ្នោត ៖ រាល់សន្លឹកឆ្នោតមានលេខ១ គឺទទួលបាន ៣ពិន្ទុ ចំណែកឯលេខ២ គឺទទួលបាន២ ពិន្ទុ និងលេខ៣ គឺទទួលបាន ១ពិន្ទុ។ (ចូរមើលនូវសេចក្តីណែនាំគ្រូ)បន្ទាប់ពីសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់។ គណៈកម្មការបោះឆ្នោតធ្វើ ការប្រកាសនូវលទ្ធផលកំពូលចំនួន១០។

អ្នកនឹងពិភាក្សាអំពីលទ្ធផលជាមួយនឹងលោកនាយកសាលា ពីព្រោះគាត់គឺជាបុគ្គលដែលត្រូវសម្រេចចិត្តទៅលើម៉ោងនៃសកម្មភាពខាងក្រៅសាលាទាំងអស់។នៅមេរៀនបន្ទាប់ អ្នកនឹងឱ្យសិស្សដឹងថា តើវាត្រូវបានយល់ព្រមឬអត់។ពេលនៅសល់ លេងល្បែង "នរណាជាអ្នកដឹកនាំ" ម្តងទៀត។

## សេចក្តីណែនាំគ្រូ

សកម្មភាពដែលអាចធ្វើបាននៅក្នុងព្រឹត្តិការណ៍ គឺ ៖

- **ថ្ងៃកីឡា** សិស្សអាចធរៀបចំល្បែងខុសៗគ្នាដើម្បីលេងនៅក្នុងបរិវេណសាលា។ ល្បែងនេះ គឺសមស្រប ទៅនឹងកុមារ និងមនុស្សពេញវ័យ។
- **ការទទួលទានអាហាររួមគ្នា**ធ្វើការទិញ ឬក៏បង្កើតក្រុមតូច ឬធំដើម្បីទទួលទានអាហារជាមួយគ្នាជាមធ្យោបាយ ល្អមួយ ដើម្បីជួបជុំមនុស្សដទៃ និងមានពេលវេលាល្អមួយផងដែរ។
- **ការជួយគ្នា**
  មានមធ្យោបាយជាច្រើនដែលសិស្សអាចជួយអ្នកដទៃបាន។ ឧទាហរណ៍ ៖ សំអាតផ្ទះ ផ្លូវ ទិញ ថ្នាំលាបផ្ទះដែលចាស់ៗ។ ការសម្របសម្រួលដ៏ល្អមួយ គឺត្រូវការ។
- **តន្ត្រីពេលយប់**ខារ៉ាអូខេមួយឈុត អាចត្រូវបានជួល ហើយមនុស្សម្នាទាំងអស់គ្នា គឺត្រូវបានអញ្ជើញឱ្យមកធ្វើ ការសំដែងនៅល្ងាចនេះផងដែរ។ វេទិកា ក្រដាសផ្សព្វផ្សាយ ឬក៏ការសំដែងរបស់សិស្សផ្ទាល់ក៏អាចត្រូវបាន រៀបចំផងដែរ។
- **ការទិញសំភ្ភារៈសម្រាប់ទីធ្លាលេងកំសាន្ត** រៀបចំដាក់នូវសម្ភារៈមួយចំនួន សម្រាប់កុមារដើម្បីលេងឬក៏បង្កើតជា កន្លែងសម្រាប់បញ្ចូលទីចំនួនមួយ ដើម្បីទុកលេងបាល់ទាត់។ នេះអាចទទួលបានតម្លៃថ្លៃប៉ុន្តែវានឹងក្លាយជាការ បរិច្ចាគដែលជួយទ្រទ្រង់ចំពោះសហគមន៍ផងដែរ។
- **ការធ្វើដំណើរ**ប្រសិនបើជាអ្នកមានលុយគ្រប់គ្រាន់ ឬក៏មានទីកន្លែងណាមួយ ដែលនៅជិតដូច្នេះអ្នកអាច រៀបចំដំណើរកំសាន្តមួយទៅកាន់រោងល្ខោន ទីធ្លាលេងកំសាន្ត កន្លែងហែលទឹក...។
- **ជួលអ្នកសំដែងម្នាក់** ក៏អាចធ្វើទៅបានផងដែរ ដើម្បីជួលនរណាម្នាក់ឱ្យមកសំដែង។ នេះអាចជាការ សម្តែង ការរាំ តន្ត្រី ល្ខោន និទានរឿង ឬក៏ព្រឹត្តិការណ៍ផ្សេងៗដែលសមស្របទៅនឹងក្រុមគោលដៅ។ ជាការ ពិត នេះអាចមានលក្ខណៈងាយស្រួលក្នុងការរៀបចំសម្រាប់សិស្ស។ ចូរពិនិត្យមើល ថាតើមានមនុស្សដែល អ្នកអាចទាក់ទងនៅក្នុងសហគមន៍ដែរឬទេ។
- **រោងជាងដែលប្រកបដោយការច្នៃប្រឌិត** មិនត្រឹមតែកុមារទេ ក៏ប៉ុន្តែមនុស្សដែលមានវ័យចាស់ជាងផងដែរ ក៏ ចូលចិត្តការផាត់ពណ៌ រូបភាព ធ្វើផ្ទាំងដី ឬក៏ការងារដែលប្រកបដោយការច្នៃប្រឌិតផ្សេងៗទៀត។ សិស្សរបស់ អ្នកអាចផ្តល់សម្ភារៈ និងគិតអំពីកិច្ចការសម្រាប់រោងជាង។ ប្រព័ន្ធនៃការរាប់សន្លឹកឆ្នោត គឺមានការស្មុគស្មាញ បន្តិចផងដែរ ក៏ប៉ុន្តែប្រហែលជាអ្នកត្រូវការជម្រើសដទៃទៀត ប្រសិនបើសកម្មភាពមិនត្រូវបានរៀចំដោយសារ តែហេតុផលណាមួយ។

# មេរៀនទី ៨: ការងារ និងឧបករណ៍

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាស និងប៊ិច
- ខ្មៅដៃ និងក្រដាសរ៉ាម សម្រាប់ធ្វើជាប័ណ្ណប្រកាស និងក្រដាសផ្សព្វផ្សាយ
- ថតចម្លងក្រដាសកិច្ចការ៨.១ សម្រាប់ក្រុមនីមួយៗ
- ថតចម្លងក្រដាសកិច្ចការ៨.២ តែម្ដង

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ទំនាក់ទំនងបានដោយប្រសិទ្ធភាពនូវការយល់ដឹងពីការងារ និងគោលបំណង
- ធ្វើការជាមួយគ្នា ព្រមទាំងសមាជិកក្រុមរបស់ពួកគេ ដើម្បីបង្កើតនូវបញ្ជីការងារមួយនិងការទទួលខុសត្រូវទាំងឡាយ
- ប៉ាន់ប្រមាណពេលវេលាថា ពេលណាដែលការងាររបស់ពួកគេត្រូវបានបញ្ចប់ និងធ្វើការឆ្ពោះទៅមុខប្រកបដោយប្រសិទ្ធភាព
- អាន និងយល់នូវផែនការរៀបចំជាមូលដ្ឋាន និងសារៈសំខាន់នៃការធ្វើការជាមួយគ្នា។

**ចំណងជើងមេរៀនទី ៨: ការងារ និង ឧបករណ៍** 🕑 ១៥ នាទី

**សកម្មភាពទី១ សេចក្ដីផ្ដើម**

ប្រាប់សិស្សអំពីការសម្រេចចុងក្រោយ ដែលទទួលបានពីលោកនាយក។

ចូរបង្កើតនូវរចនាសម្ព័ន្ធ

តើអ្នកគ្រប់ៗគ្នា មានចាំល្បែងគេបិទភ្នែក ហើយត្រូវដើរជុំវិញរង្វង់មូល ឬទេ?

ល្បែងនេះ គឺនិយាយអំពីការជឿទុកចិត្ត។ យើងត្រូវតែជឿជាក់គ្នាទៅវិញទៅមក ដើម្បីភាពប្រាកដប្រជា និងអារម្មណ៍ជឿទុកចិត្ត។ នេះ គឺជាអ្វី ដែលយើងត្រូវរៀននៅក្នុងមេរៀន។ យើងនឹងរៀបចំនូវព្រឹត្តិការណ៍មួយ ជាមួយក្រុមទាំងមូល។ គ្មាននរណាម្នាក់អាចធ្វើវាដោយម្នាក់ឯងបានទេ។ នេះ គឺជាមូលហេតុដែលយើងត្រូវជឿជាក់គ្នាទៅវិញទៅមកថាគ្រប់ៗគ្នានឹងធ្វើកិច្ចការរបស់ខ្លួន។

ដើម្បីរៀបចំឱ្យបានល្អ យើងត្រូវបែងចែកការងារទាំងឡាយមានក្រុមខុសៗគ្នាចំនួន៤៖

ផ្សព្វផ្សាយ ៖ ធ្វើការផ្សព្វផ្សាយព្រឹត្តិការណ៍នៅក្នុងសហគមន៍ កាសែត ប្រព័ន្ធផ្សាយផ្សេងៗទៀត

រៀបចំ ៖ រៀបចំសម្ភារៈចាំបាច់ទាំងឡាយ និងជួបជាមួយនឹងមនុស្សដែលជាប់ទាក់ទង

ដឹកនាំ ៖ គិតអំពីកម្មវិធី ដែលមាននៅថ្ងៃនោះ និងបែងចែកទំនួលខុសត្រូវ រវាងមនុស្សទាំងអស់គ្នា

ត្រួតពិនិត្យ ៖ បង្កើតនូវប្រព័ន្ធមួយដើម្បីពិនិត្យមើល ថាតើគ្រប់ៗគ្នាយល់អំពីកិច្ចការរបស់ ពួកគេ និងបានធ្វើវាឬក៏អត់

✎ ចូរគូរនូវផែនការ នៅទំព័របន្ទាប់នៅលើក្ដារខៀន




អ្នកត្រូវការយ៉ាងហោចណាស់ មនុស្ស ៦នាក់ នៅគ្រប់ក្រុមទាំងអស់ លើកលែងតែក្រុមត្រួតពិនិត្យ។ នោះជាក្រុមដែលគ្រូនឹងធ្វើការដឹកនាំ។ ដោយពឹងផ្អែកទៅលើចំណាប់អារម្មណ៍និងជំនាញរបស់អ្នក ដូច្នេះអ្នកអាចសម្រេចចិត្តថាក្រុមមួយណាដែលអ្នកចង់ចូលរួម។

សិស្សអាចធ្វើការសម្រេចចិត្តថា ក្រុមណាមួយដែលពួកគេចង់ចូលរួម ហើយសរសេរឈ្មោះរបស់ពួកគេនៅជុំវិញរង្វង់មូលទាំងឡាយ។

ក្រុមទាំងអស់ ត្រូវធ្វើការជាមួយគ្នាឱ្យដូចពេលដែលយើងបានធ្វើនៅក្នុងមេរៀនទី១ និង ទី២។ យើងត្រូវតែមានគម្រោង និងរៀបចំនូវព្រឹត្តិការណ៍របស់យើង។ វាអានដំណើរការបាន លុះត្រាតែយើងធ្វើការជាមួយគ្នា។ អ្នកក៏អាចប្រើប្រាស់សន្លឹកកិច្ចការ៨.១ ដើម្បីរៀបជាគម្រោង សម្រាប់សកម្មភាពរបស់អ្នក។

## សកម្មភាពទី ២: ការងារ និងឧបករណ៍សម្រាប់ធ្វើការងារ ⏲ ៦៥ នាទី

✋ ចូរផ្ដល់ឱ្យសិស្សនូវឯកសារ ៨.១ សម្រាប់សិស្ស និងត្រៀមទុកនូវឯកសារ ៨.២សម្រាប់សិស្ស។ សិស្សបង្កើតក្រុម និងយកក្រដាសកិច្ចការ៨.១។ ពួកគេនឹងមក ហើយសួររកក្រដាសកិច្ចការ៨.២ ដែលជាសេចក្ដីពណ៌នាអំពីការងារ។

នៅចុងបញ្ចប់នៃមេរៀននេះ ពួកគេត្រូវមានបញ្ជីមួយសម្រាប់បុគ្គលម្នាក់ៗ ដើម្បីធ្វើកិច្ចការ។ គ្រូនឹងធ្វើការត្រួត

ពិនិត្យអំពីបញ្ហានេះ ដោយដើរជុំវិញ ក៏ប៉ុន្តែ អ្នកក៏អាចចាត់ឱ្យក្រុមគ្រូត ពិនិត្យជាអ្នកកត់នូវឈ្មោះរបស់សិស្សទាំងឡាយ និងកិច្ចការរបស់ពួកគេក៏បានដែរ។ នេះ គឺត្រូវធ្វើការពន្យល់នៅក្នុងសេចក្តីពណ៌នាការងារដែលមាននៅក្នុងសន្លឹកកិច្ចការ៨.២។

*(!) នេះគឺជាពេលវេលាល្អផងដែរ ក្នុងការបំពេញនៅក្នុងក្រដាសវាយតម្លៃសិស្សម្នាក់ៗ។*

**សកម្មភាពទី៣ ការជឿជាក់ទៅលើក្រុមធំ** ១០ នាទី

គ្រប់ៗគ្នា កំពុងតែធ្វើការជាមួយគ្នា ស្តីអំពីព្រឹត្តិការណ៍នេះ។ ខ្ញុំគិតថា យើងបានធ្វើនូវការងារដ៏ល្អមួយ។ ឥឡូវនេះ វាអាស្រ័យទៅលើយើង ក្នុងការធ្វើបញ្ហានេះឱ្យទទួលបានជោគជ័យ។ កុំភ្លេចស្នើសុំជំនួយ ប្រសិនបើអ្នកត្រូវការវាហើយ ចំណែកឯអ្នកដទៃទៀតដែលមក ពីក្រុមរបស់អ្នក អាចជួយធ្វើកិច្ចការរបស់អ្នក។ យើងក៏ត្រូវជឿជាក់គ្នាទៅវិញទៅមកផងដែរទៅលើការធ្វើកិច្ចការនេះ។ នៅសប្តាហ៍ក្រោយ គ្រប់ៗគ្នាត្រូវតែបញ្ចប់ការងាររបស់ខ្លួន។

ចូរប្រមូលផ្តុំក្រុមជារង្វង់ធំមួយ។ ស្នើសុំអ្នកស្ម័គ្រចិត្តម្នាក់ ពាក់វ៉ែនតា ងងឹត ហើយដើរជុំវិញរង្វង់។ នៅពេលដែលពួកគេដើរដល់ម្ខាងទៀត អ្នកដែលនៅជិតគេចាប់បង្វិលគេឱ្យបែរទៅទិសផ្សេង ហើយការពារគេមិនឱ្យប៉ះទង្គិច ឬក៏ដួល។ នេះ គឺជាការជឿជាក់ និងការជួយគ្នាទៅវិញទៅមក។

## សេចក្តីណែនាំគ្រូ

- វាមានសារៈសំខាន់ណាស់ ដើម្បីដឹងពីចំនួនមនុស្សប៉ុន្មាននាក់ ដែលនឹង មកចូលរួមនៅក្នុងព្រឹត្តិការណ៍របស់អ្នក។ អ្នកត្រូវមានអាហារ សម្ភារៈ និងទីកន្លែងគ្រប់គ្រាន់សម្រាប់អ្នកចូលរួម។ ប្រសិនបើអ្នកមិនច្បាស់អំពីចំណុចនេះ អ្នកក៏អាចបង្កើតនូវ *ការអញ្ជើញផ្ទាល់ខ្លួនអ្នក* ក៏បាន ដែរ។ នេះអាចជាកិច្ចការសម្រាប់ក្រុមផ្សព្វផ្សាយរបស់អ្នក។

- ប្រសិនបើព្រឹត្តិការណ៍ធ្វើឡើងនៅក្នុងបរិវេណសហគមន៍ អ្នកប្រហែល ជាត្រូវផ្តល់ព័ត៌មានដល់លោកប្រធានសហគមន៍ ឬក៏ប៉ូលីសអំពីព្រឹត្តិការណ៍នោះ។ ប្រហែលជាពួកគេ អាចជួយអ្នកជាមួយនឹងវិធានការណ៍សុវត្ថិភាពមួយចំនួន។

- ល្បែងដែលបង្ហាញអំពីការជឿជាក់ល្អមួយផ្សេងទៀត គឺ "ល្បែងធ្លាក់"។ មនុស្សម្នាក់ឈរបែរខ្នងរបស់គេទៅកាន់មនុស្ស យ៉ាងហោចណាស់ ៤នាក់។ នៅពេលភ្លាមៗនោះផងដែរ មនុស្សទំលាក់ខ្លួនមក ក្រោយ។ ចំណែកអ្នកដទៃទៀត ឈរនៅក្រោយគេជាអ្នកចាប់គេនៅពេល ដែលគេកំពុងដួល។ ល្បែងនេះអាចលេងជាក្រុមដែលមានសិស្ស ៥នាក់ ហើយអ្នកដែលធ្វើដួល អាចផ្លាស់ប្តូរគ្នាបានគ្រប់ពេល។មធ្យោបាយនេះគឺពួកគេអាចមានបទពិសោធន៍ទៅលើអត្ថន័យ នៃការជឿជាក់លើនរណាម្នាក់។





# ត្រៀមរួចជាស្រេចដើម្បីធ្វើ



ដូច្នេះ អ្នកត្រៀមខ្លួនរួចហើយមែនទេ ដើម្បីរៀបចំព្រឹត្តិការណ៍សហគមន៍?

អស្ចារ្យ! ថ្ងៃនេះ យើងនឹងធ្វើការសម្រេចចិត្តថា តើរបស់ចុងក្រោយអ្វីដែលយើងត្រូវធ្វើ មុនពេលដែលព្រឹត្តិការណ៍នេះកើតឡើង ។

ជាដំបូង សរសេរចូលនូវក្រុមណាមួយដែលអ្នកស្ថិតនៅ (ក្រុមរៀបចំ, ត្រួតពិនិត្យ, ផ្សព្វផ្សាយ, ឬក៏ដឹកនាំ) ។

---

ឥឡូវនេះ ប្រសិនបើអ្នកចង់ដឹងថាអ្វីដែលអាចជាកិច្ចការរបស់អ្នក អ្នកគួរតែអានសេចក្តី ណែនាំអំពីការងារដោយប្រុងប្រយ័ត្ន ។ នរណាម្នាក់ដែលមកពីក្រុមរបស់អ្នក អាចមកយកវាពីលោក/អ្នកគ្រូ ។

អ្នកណាម្នាក់ អាចអាននូវសេចក្តីពិពណ៌នាអំពីការងារឱ្យបានឮៗ ដូច្នេះគ្រប់ៗគ្នាអាចស្តាប់ឮ នូវអ្វីដែលសេចក្តីពិពណ៌នានោះនិយាយអំពី ។ តើអ្នកយល់នូវអ្វីដែលអ្នកត្រូវធ្វើដែរឬទេ? ប្រសិនបើមិនយល់ សរសេរសំនួររបស់អ្នក ហើយយកវាទៅឱ្យគ្រូ ដើម្បីឱ្យគាត់ធ្វើការពន្យល់ ។

ប្រសិនបើអ្នកយល់នូវអ្វីដែលត្រូវធ្វើ អ្នកនឹងត្រូវការធ្វើការបែងចែកការងារទាំងឡាយ។

អាន: កិច្ចការ និងសម្រេចចិត្តថា នរណាម្នាក់ដែលអាចធ្វើវាបានល្អបំផុត ជាការពិតអ្នកអាចធ្វើការជ្រើសរើសមនុស្សពីរនាក់ ដែលអាចធ្វើការជាមួយគ្នា ។

សរសេរចូលនៅក្នុងតារាងខាងក្រោម :

| ឈ្មោះ | កិច្ចការ | ពេលណាបញ្ចប់? |
| --- | --- | --- |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

នៅពេលដែលគ្រប់ៗគ្នាដឹងអ្វីដែលត្រូវធ្វើ វាជាពេលមួយដែលត្រូវចាប់ផ្តើមធ្វើ !

កិច្ចការមួយចំនួន អ្នកនឹងត្រូវធ្វើបន្ទាប់ចេញពីសាលា ក៏ប៉ុន្តែក្នុងនាមជាសហគ្រិនដ៏ពិតប្រាកដមួយរូប អ្នកនឹងត្រូវបញ្ចប់នូវរាល់សកម្មភាពរបស់អ្នកឱ្យទាន់ពេល ។ សូមមានសំណាងល្អ!

## សេចក្តីពិពណ៌នាការងារ សម្រាប់ក្រុមត្រួតពិនិត្យ

យើងកំពុងតែធ្វើការស្វែងរកមើលមនុស្សណា ដែលអាចធ្វើការជាក្រុម ទៅលើការពិនិត្យពិច័យ និងគ្រប់គ្រងនូវកិច្ចការខុសគ្នាមួយចំនួន។ អ្នកនឹងធ្វើការជាមួយ និងអ្នកគ្រប់គ្រង(គ្រូ) ហើយនឹងត្រូវត្រួតពិនិត្យមើលក្រុមដទៃទៀតផងដែរដោយការផ្តល់មតិយោបល់ និងសរសើរពួកគេ ។



គោលបំណង: ក្រុមត្រួតពិនិត្យ នឹងមានបញ្ជីដែលបំពេញរួចមួយសម្រាប់កិច្ចការនិងការទទួលខុសត្រូវ ហើយក៏ត្រូវធ្វើការត្រួតពិនិត្យមើលផងដែរ ថាតើរាល់កិច្ចការទាំងអស់ត្រូវបានធ្វើរួច ។

**កិច្ចការ :**

- អ្នកនឹងចាត់ចែងឲ្យសមាជិក២នាក់នៃក្រុមរបស់អ្នក ជាអ្នកទាក់ទងជាមួយក្រុមដទៃ។ ពួកគេនឹងផ្តល់ព័ត៌មានទៅកាន់ក្រុមដទៃអំពីលុយដែលរកបាន។
- អ្នកនឹងធ្វើការជាមួយ នឹងអ្នកគ្រប់គ្រងគ្រូ ដោយបង្កើតបញ្ជីមួយដែលមានឈ្មោះសមាជិកនៃមិត្តរួមថ្នាក់ទាំងអស់។ នៅពីក្រោយឈ្មោះទាំងអស់នោះ អ្នកសរសេរនូវរាល់កិច្ចការដែលពួកគេត្រូវធ្វើ។
- អ្នកនឹងត្រួតពិនិត្យមើលសៀវភៅកត់ត្រាលុយ និងលុយមួយចំនួនទៀត ។ លុយទាំងអស់ដែលត្រូវបានផ្តល់ទៅឲ្យសមាជិកក្រុម ត្រូវតែសរសេរចូលជាមួយគ្រូ។ ចូរផ្តល់នូវព័ត៌មានទៅកាន់សមាជិកដទៃថា ពួកគេត្រូវតែសុំវិក័យបត្រនៅរាល់ពេលដែលទិញរបស់អ្វីមួយ ។

## សេចក្តីពិពណ៌នាការងារ សម្រាប់ក្រុមដឹកនាំ



យើងកំពុងស្វែងរកមើលនរណាម្នាក់ ដែលអាចដឹកនាំនូវព្រឹត្តការណ៍នោះ ដោយខ្លួនពួកគេផ្ទាល់ ។ មនុស្សទាំងអស់នេះ ត្រូវតែសកម្ម និងអាចណែនាំក្មេងដទៃៗទៀត ឬមនុស្សវ័យជំទង់ពីកិច្ចការដែលពួកគេត្រូវធ្វើ ។

អ្នកត្រូវមានភាពរួសរាយរាក់ទាក់ ក៏ប៉ុន្តែត្រូវមានភាពក្លាហានក្នុងការសម្រេចចិត្ត ឬក៏ធ្វើការស្នើសុំនូវជំនួយពីគ្រូ ។

គោលបំណង: ក្រុមដឹកនាំ នឹងត្រូវធ្វើបទបង្ហាញនូវកម្មវិធីដែលនឹងកើតមានសម្រាប់ថ្ងៃនោះដោយខ្លួនរបស់ពួកគេទៅកាន់អ្នកចូលរួមទាំងឡាយស្តីអំពីព្រឹត្តិការណ៍នោះ ។

**កិច្ចការ:**

- អ្នកនឹងត្រូវស្វាគមន៍រាល់អ្នកចូលរួមទាំងអស់ ហើយនិយាយទៅ កាន់ពួកគេដោយប្រើមីក្រូហ្វូន ។
- អ្នកនឹងពន្យល់អំពីកម្មវិធីនោះទៅកាន់អ្នកចូលរួមទាំងឡាយ ហើយនឹងប្រាប់ពួកគេថា ពេលណាដែលពួកគេត្រូវធ្វើអ្វី ។
- អ្នកនឹងសួរគ្រូ នៅពេលណាដែលអ្នកមិនច្បាស់អំពីកិច្ចការដែលត្រូវធ្វើ ក្នុងករណីដែលកើតមានបញ្ហាខុសពីការរំពឹងទុក ។

## សេចក្តីពិពណ៌នាការងារ សម្រាប់អ្នករៀបចំ



យើងកំពុងស្វែងរកក្រុមមួយដែលមានភាពសប្បាយរីករាយខ្លាំងហើយអាចជួយយើងក្នុងការរៀបចំព្រឹត្តិការណ៍នេះ ។ ពួកគេត្រូវធ្វើការជាមួយគ្នា និង ធ្វើការផ្តល់យោបល់ ក៏ដូចជាការសរសើរចំពោះគ្នាទៅវិញទៅមក ។

គោលបំណង : អ្នកត្រូវត្រួតពិនិត្យមើលថ្នាក់របស់ពួកយើងហើយអ្នកក៏ត្រូវរៀបចំនូវសម្ភារ, ឧបករណ៍, និងរបស់របរចាំបាច់មួយចំនួនទៀតដែលយើងត្រូវការសម្រាប់ព្រឹត្តិការណ៍របស់យើង

**កិច្ចការ:**

- បង្កើតបញ្ជីមួយសម្រាប់សម្ភារទាំងអស់ ដែលត្រូវការសម្រាប់ព្រឹត្តិការណ៍របស់យើង
- បង្កើតបញ្ជីមួយសម្រាប់សម្ភារៈទាំងឡាយណាដែលយើងអាចខ្ចី និងសម្ភារៈដែលយើងត្រូវការ *ទិញ*
- ជ្រើសរើសមនុស្ស២នាក់ ដើម្បីរៀបចំសម្ភារៈដែលយើងអាចខ្ចីបាន
- ជ្រើសរើសមនុស្ស២នាក់ ដើម្បីត្រួតពិនិត្យតម្លៃសម្រាប់សម្ភារៈទាំងអស់ ដែលយើងត្រូវទិញ និងទាក់ទងទៅក្រុមត្រួតពិនិត្យ ដើម្បីឲ្យធ្វើការពិនិត្យមើលថាតើយើងអាចចំណាយទៅលើសម្ភារៈទាំងនោះបានឬទេ
- ទាក់ទងទៅកាន់ក្រុមត្រួតពិនិត្យដើម្បីប្រាប់ពួកគេ ពីភារៈកិច្ចរបស់សមាជិកម្នាក់ៗ ក្នុងក្រុម។

---

## សេចក្តីពិពណ៌នាការងារ សម្រាប់អ្នកផ្សព្វផ្សាយ



ការរៀបចំរបស់យើង គឺចង់បានអ្នកផ្សព្វផ្សាយដែលមានភាពសប្បាយរីករាយខ្លាំងជាមួយនឹងការងារ និងមានគំនិតច្នៃប្រឌិតផងដែរ ដែលអាចផ្សព្វផ្សាយអំពីព្រឹត្តិការណ៍របស់យើងទៅក្រុមគោលដៅ ។ ការធ្វើការជាមួយគ្នា, ការជួយជាគំនិត និងការសរសើរ គឺពិតជាសំខាន់ ។

គោលបំណង: អ្នកនឹងឲ្យមនុស្សទាំងអស់គ្នាដឹងថា ព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើង ដើម្បីនរណាគេ ។ អ្នកក៏នឹងឲ្យពួកគេដឹងអំពីពេលវេលា និងទីកន្លែងដែលព្រឹត្តិការណ៍នឹងចាប់ផ្តើមកើតឡើង ហើយប្រសិនបើពួកគេត្រូវការយកអ្វីមកជាមួយ គឺពួកគេអាចយកដោយខ្លួនពួកគេ ។ **កិច្ចការ:**

- បង្កើតផ្ទាំងរូបភាពធំៗ ដែលអាចដាក់ព្យួរនៅតាមកន្លែងខុសៗគ្នា នៅក្នុងតំបន់
- គិតអំពីមធ្យោបាយផ្សេងៗ ដើម្បីផ្សព្វផ្សាយពីព្រឹត្តិការណ៍របស់យើង (ឧ.ខិតប័ណ្ណផ្សព្វផ្សាយ)
- ទាក់ទងជាមួយនឹងសារព័ត៌មាន និងការផ្សាយដើម្បីធ្វើការរាយការណ៍ អំពីព្រឹត្តិការណ៍នៅថ្ងៃនោះ
- ផ្តល់ព័ត៌មានទៅកាន់សិស្ស អំពីសកម្មភាពនៅក្នុងសាលារបស់អ្នក
- ទាក់ទងទៅកាន់ក្រុម**ត្រួតពិនិត្យ** ដើម្បីអោយពួកគេដឹង ពីភារៈកិច្ចរបស់សមាជិកម្នាក់ៗ ក្នុងក្រុម។

# មេរៀនទី ៩: ការកំណត់

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន ( តុ កៅអី ក្តារខៀន... )

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ក្រដាសសមួយចំនួន
- កាសែតចំរៀង

☼ **វត្ថុបំណង**

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ប្រាប់ពីអារម្មណ៍របស់ពួកគេនៅពេលនោះ និងគិតអំពីហេតុផលសម្រាប់អារម្មណ៍នោះផងដែរ
- រាយការណ៍ទៅកាន់ក្រុមអំពីការខិតខំប្រឹងប្រែងរបស់ពួកគេផ្ទាល់
- បង្ហាញពីទំនួលខុសត្រូវរបស់ពួកគេនៅក្នុងព្រឹត្តិការណ៍ដែលនឹងកើតឡើង។

**ចំណងជើងមេរៀនទី ៩: ការកំណត់** 🕑 ១០ នាទី

**សកម្មភាពទី១ សេចក្តីផ្តើម**

នៅពេលដែលសិស្សទាំងអស់គ្នាចូលទៅក្នុងថ្នាក់ ចែកប័ណ្ណមួយសន្លឹក ប៊ិចមួយដើម និងកាសែតចំរៀងចំនួនមួយដុំ។ ស្នើពួកគេឱ្យសរសេរចូល ដោយមិនឱ្យលើសពីបីពាក្យ អំពីការគ្រប់គ្រងអារម្មណ៍របស់ពួកគេនៅពេលភ្លាមៗនោះ។ ចំពោះប័ណ្ណដែលបានសរសេររួច គឺត្រូវបិទនៅ លើអាវ/ផ្នែកខាងលើជាមួយនឹងកាសែតចំរៀង។

សិស្សទាំងអស់គ្នាអាចដើរជុំវិញបន្ទប់រៀន ដោយក្រឡេកមើលទឹកមុខគ្នាទៅវិញទៅមក និងសាកសួរនូវអារម្មណ៍របស់ពួកគេទៅវិញទៅមកផងដែរ។ បន្ទាប់ពីពួកគេស្វែងរកឃើញ និងទទួលបាននូវការបញ្ជាក់ច្បាស់លាស់រួចហើយ ចូរឱ្យពួកគេបង្កើតជាក្រុមសម្រាប់អ្នកដែលមានអារម្មណ៍ដូចគ្នា។

**សកម្មភាពទី២ ការកំណត់** 🕑 ៧០ នាទី

សិស្សទាំងអស់ ប្រមូលផ្តុំគ្នាតាមក្រុមរបស់ពួកគេ។ ក្រុមនីមួយៗត្រួតពិនិត្យមើលនូវ រាល់កិច្ចការរបស់ពួកគេ ដើម្បីឱ្យប្រាកដថា អ្វីគ្រប់យ៉ាងត្រូវបានធ្វើរួច។

គ្រូដើរជុំវិញក្រុមធំ ដើម្បីត្រួតពិនិត្យមើលថា តើពួកគេបានត្រួតពិនិត្យមើលនូវរាល់កិច្ចការទាំងអស់ដែរ ឬទេនិងមានសល់បញ្ហាណាមួយចំពោះចំណុចនេះ។

ក្រុមទាំងអស់មានរយៈពេលខ្លី ដើម្បីរាយការណ៍ទៅកាន់សមាជិកនៅក្នុងក្រុម។ ពួកគេនឹងមានរយៈពេលពីរឬបីនាទីដើម្បីឈរជាក្រុមនៅមុខមិត្តរួមថ្នាក់ និងប្រាប់នូវកិច្ចការដែលត្រូវបានធ្វើរួច និងកិច្ចការដែលមិនទាន់ធ្វើរួច។ បន្ទាប់មកវាគឺជាពេលធ្វើការត្រួតពិនិត្យចុងក្រោយ។ គ្រូធ្វើការងារនេះជាមួយនឹងសិស្សទាំងអស់គ្នា។ នៅពេលដែលសិស្សផ្តល់ចម្លើយ ចូរសាកសួរពួកគេឱ្យពន្យល់បានច្បាស់នូវ សំណួរម្តងមួយៗ។

ឧទាហរណ៍៖ តើសម្ភារៈណាមួយដែលអ្នកមាន? ឬតើអ្នកដាក់ផ្ទាំងរូបភាពធំៗនៅកន្លែងណា?

អ្នករៀបចំ

- តើអ្នកមានគ្រឿងបរិក្ខារទាំងអស់ទេ?
- តើកន្លែងណាដែលយើងនឹងរក្សាទុកគ្រឿងបរិក្ខារទាំងអស់នោះ? (នៅជិតកន្លែងព្រឹត្តិការណ៍ពិតប្រាកដ)
- តើចំនួនលុយប៉ុន្មានដែលអ្នកត្រូវចំណាយជាសរុប ហើយតើអ្នកបានរាយការណ៍ទៅ កាន់*ក្រុមត្រួតពិនិត្យដែរឬទេ*?

អ្នកផ្សព្វផ្សាយ

- តើផ្ទាំងរូបភាពទាំងអស់នោះត្រូវបានបិទផ្សាយហើយឬនៅ?
- តើប្រជាជនទាំងអស់ដែលមកពី*ក្រុមគោលដៅ*ដឹងពីពេលវេលា ទីកន្លែង និង ព្រឹត្តិការណ៍នេះត្រូវបានប្រាប់ឡើងដើម្បីនរណាទេ?
- តើពួកគេដឹងឬនៅ ថាពួកគេត្រូវយកអ្វីមកជាមួយ?

អ្នកដឹកនាំ

- តើអ្នកមានតារាងពេលវេលាសម្រាប់កម្មវិធីរបស់ពួកយើងដែរឬទេ? តើយើងចាប់ផ្តើមនៅពេលណា និងនឹងបញ្ចប់នៅពេលណា?
- តើអ្នកបានរៀបចំនូវអ្វី ដែលត្រូវនិយាយទៅកាន់សាធារណជន ហើយឬនៅ?
- តើអ្នកមានបានគិតអំពីអ្វីមិនល្អដែលអាចកើតឡើងដែរឬទេ ហើយដោះស្រាយវាដោយវិធីណា?

អ្នកត្រួតពិនិត្យ

- តើចំនួនលុយប៉ុន្មានដែលត្រូវបានចំណាយដោយក្រុមទាំងអស់?
- តើលុយប៉ុន្មានដែលនៅសល់?(មើលសេចក្តីណែនាំគ្រូ)

យើងនឹងអនុវត្តនូវព្រឹត្តិការណ៍នោះ។ នេះអាចហៅបានថា ជាការហាត់សមសំលៀកបំពាក់។ ប្រសិនបើអាច ចូរធ្វើការអនុវត្តន៍នៅកន្លែងប្រារព្ធព្រឹត្តិការណ៍នោះតែម្តង ព្រមទាំងជាមួយនឹងសម្ភារៈទាំងអស់ដែល ចាំបាច់ផងដែរ។ សិស្សទាំងអស់គ្នាត្រូវ ៖

- អនុវត្តនូវអ្វីដែលត្រូវនិយាយ ចំពោះតួនាទីរបស់ពួកគេ (ឧទាហរណ៍ ៖ និយាយទៅកាន់សាធារណៈជន ដោយពន្យល់អំពីល្បែងលេងទៅកាន់កុមារ)។ ពួកគេអាចអនុវត្តបែបនេះជាដៃគូ។ ប្រសិនបើនរណាម្នាក់កំពុងពន្យល់ ឬក៏ពិភាក្សាគ្នា អ្នកដទៃអាចសួរពួកគេនូវសំណួរមួយចំនួន ដោយធ្វើពុតជាមិនដឹងចម្លើយ។
- ដឹងនូវពេលវេលា ដែលព្រឹត្តិការណ៍នឹងកើតឡើង ដូច្នេះពួកគេទាំងអស់គ្នាអាចជួយគ្នា ក្នុងការត្រៀមសម្ភារៈដែលត្រូវការមួយចំនួនសម្រាប់រៀបចំក្នុងព្រឹត្តិការណ៍នោះ។ ដោយពឹងផ្អែកទៅលើទំហំនៃព្រឹត្តិការណ៍ ដូច្នេះអ្នកចង់ឱ្យពួកគេមានវត្តមាននៅកន្លែងប្រារព្ធពិធីយ៉ាងហោចណាស់ រយៈពេលមួយម៉ោងមុនពេលពិធីចាប់ផ្តើម។
- ទាំងអស់គ្នាត្រូវដឹងអំពី តារាងពេលវេលាសម្រាប់ព្រឹត្តិការណ៍ទាំងមូល កិច្ចការអ្វីដែលត្រូវ ធ្វើនៅពេលមានបញ្ហាអ្វីមួយកើតឡើង ហើយមិនអាចដោះស្រាយបាន។
- ត្រូវមានភាពសប្បាយរីករាយ ចូលរួម និងត្រូវមានភាពសកម្ម។

គ្រូត្រូវតែមានភាពច្បាស់លាស់ថា រាល់សម្ភារៈទាំងអស់ដែលត្រូវការ សម្រាប់ព្រឹត្តិការណ៍ គឺត្រូវបានរៀប ចំរួចរាល់ ទីតាំងប្រារព្ធពិធីកំណត់កន្លែងច្បាស់លាស់ និងបញ្ជាក់សិស្សពីចំណុចសំខាន់ដែលត្រូវនិយាយក្នុងបទបង្ហាញរបស់ពួកគេ។

## សកម្មភាពទី៣ រូបភាពនៃម៉ោង

១០ នាទី

គ្រប់ៗគ្នាត្រូវនាំគ្នាឈរជារង្វង់មួយ។

ចូរពន្យល់ថា អ្នកនឹងហៅពេលវេលា។ ឱ្យសិស្សបង្កើតជារូបភាពមួយដើម្បី បង្ហាញនូវអ្វីដែលពួកគេកំពុងតែធ្វើនៅក្នុងពេលនោះ។ ប្រសិនបើអ្នកស្រែកថា ម៉ោង៤ព្រឹក ភាគច្រើននៃពួកគេ នឹងធ្វើត្រាប់តាមដោយធ្វើជាដេក។ អនុវត្តចំពោះមធ្យោបាយរបស់ អ្នកតាមរយៈថ្ងៃ នីមួយៗ។

ចុងបញ្ចប់៖ ប្រាប់សិស្សថា អ្នកមានការជឿជាក់ទៅលើព្រឹត្តិការណ៍ នេះនឹង មានភាពសប្បាយរីករាយ។ សិស្សត្រូវចាកចេញពីថ្នាក់ ដោយសប្បាយរីករាយ ព្រមទាំងមានអារម្មណ៍វិជ្ជមានផងដែរ។



## សេចក្តីណែនាំគ្រូ

● លុយនៅសល់អាចត្រូវបានប្រើប្រាស់ ដើម្បីរៀបចំប្រារព្ធពិធីមួយនៅក្នុងមេរៀនទី១០។ សិស្សទាំងអស់គ្នាសមនឹងទទួលបាននូវការសរសើរ ហើយនំនិងភេសជ្ជៈមួយ ចំនួនក៏អាចត្រូវ បានទិញផងដែរ។ ប្រសិនបើគ្រូវចំណាយប្រាក់ច្រើនលោកនាយក ក៏អាចត្រូវសន្សំសំចៃថវិកាខ្លះទុកសម្រាប់ព្រឹត្តិការណ៍ដទៃៗទៀត។ វាជាការពិតណាស់ កិច្ចការទាំងអស់ត្រូវតែស្ថិតនៅក្រោមការ ត្រួតពិនិត្យរបស់ថ្នាក់នេះ។

● ចំពោះព្រឹត្តិការណ៍វិញ វាត្រូវតែមានមនុស្សវ័យជំទង់មួយចំនួនបន្ថែមទៀត ដើម្បីជួយ។ វាពិតជាមានប្រយោជន៍ណាស់ នៅពេលដែលមានបញ្ហាអ្វីមួយកើតឡើងដោយមិនបានរំពឹងទុក។ ត្រូវត្រៀម សម្ភារៈសង្គ្រោះបឋម ដូចជាទឹកឱ្យបានគ្រប់គ្រាន់។ ប្រសិនបើមានមនុស្សវ័យជំទង់ចូលរួមបន្ថែមអ្នកត្រូវតែណែនាំឱ្យសិស្សដទៃទៀតស្គាល់ ដូច្នេះពួកគេដឹងថា នរណាដែលពួកគេត្រូវធ្វើការទាក់ទង។

● វាក៏មានសារៈសំខាន់ផងដែរ ក្នុងការសួរយោបល់គ្រូដទៃទៀត នៅពេល ដែលហាត់សមនូវសំលៀកបំពាក់។ ចំពោះមធ្យោបាយនោះ គឺគ្រូត្រូវត្រួតពិនិត្យ និងសាកសួរសិស្សទាំងអស់គ្នា ពីកិច្ចការដែលពួកគេត្រូវធ្វើហើយឱ្យពួកគេរាយការណ៍អំពីវា។ ធ្វើដូច្នោះ អាចជួយអ្នកក្នុងការបំពេញនូវធាតុមួយចំនួន ក្នុងក្រដាសវាយតម្លៃសិស្សម្នាក់ៗ។

# មេរៀនទី ១០: ការបញ្ចប់

🕑 រយៈពេលបង្រៀនៈ ១ម៉ោង ៣០នាទី

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ប្រហែលជាមាននូវរូបថតមួយចំនួន ដែលបានថតនៅក្នុងព្រឹត្តិការណ៍នោះ ប្រសិនបើមាន
- ក្រដាសរ៉ាម ពណ៌សមួយសន្លឹកសម្រាប់សិស្សម្នាក់ៗ
- ខ្មៅដៃ គូល័រ ឬប៊ិចមួយចំនួន
- កាសែតចំរៀងដែលជាប់គ្នា
- នំ ភេសជ្ជៈ ពែង កាំបិតសម្រាប់កាត់នំ
- វិញ្ញាសាសរសេរ សម្រាប់សិស្សគ្រប់គ្នា

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច៖

- ផ្ដល់នូវមតិរិះគន់វិជ្ជមាន ចំពោះខ្លួនផ្ទាល់ និងអ្នកដទៃទៀត
- ប្រាប់ពីមធ្យោបាយដែលមានភាពច្នៃប្រឌិត
- បង្កើតឡើងវិញនូវចំណេះដឹង និងបទពិសោធន៍ទាំងឡាយ ដែលត្រូវបានបង្រៀន និងសិក្សានៅក្នុងវគ្គនេះ

**ចំណាយជើងមេរៀនទី ១០: ការបញ្ចប់** 🕑 ១០ នាទី

**សកម្មភាពទី១ សេចក្ដីផ្ដើមៈ ប្រារព្ធ**

✋ នៅពេលដែលសិស្សចូលមកក្នុងថ្នាក់ វាពិតជាសំខាន់ ក្នុងការលើកសរសើរពីស្នាដៃមួយចំនួន របស់ពួកគេ។ ការរៀបចំព្រឹត្តិការណ៍មួយ គឺជាកិច្ចការមួយដែលបង្រៀនពួកគេឱ្យចេះ*រៀបចំ គិតបានជិតដល់ ដោះស្រាយបញ្ហា វិភាគធនធាន និងបង្កើតនូវផែនការណ៍*។ សមត្ថភាពរបស់ពួកគេក្នុងការរៀបចំព្រឹត្តិការណ៍នេះជួយពួកគេត្រៀមខ្លួនបានយ៉ាងល្អប្រសើរ សម្រាប់កិច្ចការរបស់ពួកគេនា ពេលក្រោយទៀត។

គួរតែទិញវត្ថុអ្វីមួយដែលពិសេស ឬក៏ជាភេសជ្ជៈមួយចំនួនផងដែរ ដើម្បីធ្វើការប្រារព្ធឡើង។ ចំពោះលុយដែលរកបានដោយសហាគ្រាស ក៏អាចប្រើប្រាស់បានសម្រាប់ការប្រារព្ធនេះដែរ ក៏ប៉ុន្តែត្រូវមានការយល់ព្រមជាមុនពីមិត្តរួមថ្នាក់ទាំងអស់គ្នា។

## សកម្មភាពទី២ សកម្មភាពសំខាន់។

🕑៥០ នាទី

ឱ្យសិស្សទាំងអស់គ្នាបង្កើតជាក្រុមមួយដូចជាក្រុមដែលពួកគេធ្លាប់បានបង្កើត នៅពេលពួកគេកំពុងធ្វើការរៀបចំព្រឹត្តិការណ៍។ ផ្តល់ក្រដាសសស្អាតឱ្យក្រុមនីមួយៗ។ (ល្អជាងគេគឺ ក្រដាសទំហំ A3)បន្ទាប់ពីសរសេរឈ្មោះរបស់ពួកគេ សិស្សទាំងអស់ត្រូវនាំគ្នាគិត អំពីសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេម្នាក់ៗ និងសកម្មភាពរបស់សមាជិកម្នាក់ទៀតដែលមកពីក្រុមផ្សេង។ សិស្សទាំងអស់គ្នាត្រូវសរសេរនូវការចូលរួមវិជ្ជមានមួយ ពីសមាជិកទាំងអស់ នៅក្នុងដំណើរព្រឹត្តិការណ៍។




ឧទាហរណ៍ ៖ ជួយរៀបចំដំឡើងម៉ាស៊ីនខារ៉ាអូខេ មានគំនិតល្អអំពីល្បែងមួយដើម្បីលេង ឬក៏បានជួយ ក្នុងការសម្រេចចិត្តជ្រើសរើសតន្ត្រី ស្គាល់កន្លែងទិញ ក្រដាសពណ៌ស។ល។ ការងារទាំងអស់នោះ អាចមានភាពពិបាកសម្រាប់សិស្សទាំងអស់គ្នា ក៏ប៉ុន្តែលើកទឹកចិត្តពួកគេឱ្យគិតស៊ី ជម្រៅ វាមិនមានជាអ្វីដែលធំដុំនោះទេ។

សួរ ៖ តើបុគ្គលម្នាក់នោះបានធ្វើអ្វី ដែលអ្នកគិតថាល្អ ហើយតើគាត់/នាងបាននិយាយអ្វីដែលមានប្រយោជន៍ដែរឬទេ?

ជាចុងក្រោយមានការសន្មតល្អៗមួយចំនួន បន្ថែមទៅលើឈ្មោះនៅលើក្រដាស។ ក្រុមដែលធ្វើលឿនអាចតុបតែងក្រដាសរបស់ពួកគេដោយការគូររូប ឬក៏អាចធ្វើការនឹកគិតនូវការសន្មត ល្អណាមួយ ក្នុងចំណោមការសន្មតទាំងអស់ដោយគូររូបបញ្ជាក់ផងដែរ។ នៅពេលដែលគ្រប់គ្នាត្រូវបញ្ចប់ ការងារនេះក្រុមនីមួយៗឈរនៅខាងមុខមិត្តរួមថ្នាក់ ហើយធ្វើបទបង្ហាញទៅវិញទៅមក។

ឧទាហរណ៍ ៖ នេះគឺជាចាន់ថុល។ គាត់បានជួយយើង ក្នុងការរក្សាសៀវភៅកំណត់ប្រាក់រហូតមកដល់បច្ចុប្បន្ន។ បន្ទាប់ពីការប្រកាសនេះ មិត្តរួមថ្នាក់ទាំងអស់ផ្តល់នូវការទះដៃខ្លាំងៗទាំងអស់គ្នា។

ចែកវិញ្ញាសាសរសេរទៅកាន់សិស្ស

នៅក្នុងការធ្វើតេស្តនេះ សិស្សនឹងមាន១០សំណួរ។ ពួកគេត្រូវសរសេរចូលនូវគំនិតរបស់ពួកគេ។ ពេលពួកគេគិតថា គេបានធ្វើតេស្តរួចហើយ ពួកគេអាចឱ្យក្រដាសចំឡើយទៅគ្រូ និងភ្លាមៗនោះ ចាប់ផ្តើមនូវសកម្មភាពបញ្ចប់។ ដូច្នេះគ្រូអាចពន្យល់អំពីវាមុនពេល ពួកគេចាប់ផ្តើមធ្វើតេស្ត។

**សកម្មភាពទី៣ ចុងបញ្ចប់** ⌚ ៣០ នាទី

គ្រប់ៗគ្នាទទួលបានក្រដាសសមួយសន្លឹក។

នៅពេលដែលសិស្សទាំងអស់គ្នា បានបញ្ចប់ នូវការធ្វើតេស្តរបស់ពួកគេ ចូរធ្វើការសាកសួរ

នរណាអាចប្រាប់ខ្ញុំបាន តើលំហាត់យ៉ាងម៉េច ដែរ?

ខ្ញុំចង់ឱ្យអ្នកគិតអំពីអ្វីមួយ ដែលសប្បាយចិត្ត ដែលបានកើតឡើង នៅអំឡុងពេលព្រឹត្តិការណ៍នោះ។ បន្ទាប់មក អ្នកនឹងគូររបស់នោះ ហើយជួយធ្វើវាឱ្យមើលទៅ ជាលក្ខណៈសិល្បៈមួយបែបផងដែរ។

ឧទាហរណ៍៖ ស្នាមញញឹមប្អូនប្រុសរបស់ខ្ញុំ ល្បែងដែលធ្វើឱ្យមនុស្សសើច វិធីដែលយើងច្រៀងជាមួយគ្នា។ អនុញ្ញាតឱ្យសិស្សដទៃទៀត ស្នើនូវប្រធានបទ ដែលអាចកើតមាន។បន្ទាប់ពីនេះមកផ្តល់នូវសម្ភារៈទាំងអស់ ដែលត្រូវចែកជូន ហើយឱ្យពួកគេគូរ។ចំពោះរូបគំនូរ សិស្សទាំងអស់គ្នាអាច បិទនៅកន្លែងណាដែលមនុស្សជាច្រើន អាចមើលឃើញវា។ នេះគឺអាចបិទនៅក្នុងសាល របស់សាលា ឬក៏នៅជិតច្រកចូល។

## សេចក្តីណែនាំគ្រូ

ដោយផ្អែកទៅលើពេលវេលាដែលនៅសល់បន្ទាប់ពីសរសេរការវាយតម្លៃអ្នកក៏អាចសម្រេចចិត្តឱ្យសិស្សធ្វើការជាក្រុមធ្លុះដើម្បីបញ្ចាំង ពីការច្នៃប្រឌិតរបស់ពួកគេ។ នេះមានន័យថា ឱ្យសិស្ស ៥ នាក់ផ្សេងទៀត គូររូបមួយ ដែលសិស្សម្នាក់ៗ អាចបញ្ចូលនូវ"អ្វីមួយដែលសប្បាយ"។ របស់ទាំងអស់ នេះ អាចត្រូវបានភ្ជាប់គ្នាទៅវិញទៅមក តាមវិធីមួយដែលវាមើលទៅនៅតែជាសិល្បៈមួយបែប។





១. ចូរបង្ហាញរបស់អ្វី ដែលមានសារៈសំខាន់ចំនួន៣ នៅពេលដែលអ្នកធ្វើការជាមួយ គ្នានៅក្នុងក្រុម ។ ចូរពន្យល់ហេតុអ្វីបានជាវាសំខាន់ ។

២. ហេតុអ្វីការបង្កើតតារាងពេលវេលា នៅពេលធ្វើការងារជាក្រុមមានសារៈសំខាន់ ?

៣. នៅក្នុងម៉ូឌុលនេះ យើងបានសិក្សាអំពី *ការផ្តល់មតិយោបល់* និង *ការសរសើរ* ។ ហេតុអ្វីបានជាយើងគួរតែធ្វើវាទាំងពីរ នៅពេលដែលយើងនិយាយអំពីការខិតខំប្រឹងប្រែងពីនរណាម្នាក់?

៤. តើសិទ្ធិកុមារជាអ្វី? ចូរសរសេរសិទ្ធិយ៉ាងហោចណាស់ឱ្យបាន៣ ។

៥. ហេតុអ្វីការលេងពិតជាមានសារៈសំខាន់?

៦. '*អ្នកដឹកនាំល្អម្នាក់ គឺជាចំណុចសំខាន់បំផុតនៅក្នុងក្រុមមួយ*' ។ តើអ្នកយល់ព្រមទេ? ហេតុអ្វីបានអ្នកមិនយល់ព្រម?

៧. ករណីសិក្សា: សុខា រស់នៅក្នុងទីក្រុងភ្នំពេញ ហើយមានអាយុ១០ឆ្នាំ ។ គាត់ក៏ធ្លាប់ទៅសាលាផងដែរ ។ គ្រួសាររបស់គាត់ គឺមានជីវភាពក្រីក្រ ដោយសារតែឪពុករបស់គាត់បានបាត់បង់ការងារ ។ ឥឡូវនេះ ពួកគេអាចរកបានប្រាក់កំរៃមួយចំនួនដោយការប្រមូលផង់ប្លាស្ទិចយកទៅលក់ ។ សុខា ត្រូវតែជួយឪពុកម្តាយរបស់គាត់ ដោយសារតែពួកគេមិនមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ។

តើអ្វីខ្លះដែលជាលទ្ធផលវិជ្ជមាន និងអវិជ្ជមាន ដោយសារតែសុខាចាកចេញពីសាលារៀន? ចូរសរសេរចូលនៅក្នុងតារាងមួយ ។

តើអ្នកផ្តល់ដំបូន្មានណាមួយសម្រាប់សុខាទេ?

៨. តើអ្វីខ្លះដែលជាការសម្រេចបានសំខាន់បំផុតរបស់អ្នក ក្នុងការរៀបចំព្រឹត្តិការណ៍ ? ចូរពន្យល់ហេតុផល។

៩. តើអ្វីជាសៀវភៅតក់ត្រាចំនួនលុយ?

១០. តើអ្វីជារបស់សំខាន់បំផុត ដែលអ្នកបានរៀននៅក្នុងម៉ូឌុលនេះ? ចូរពន្យល់ហេតុផល។



**ចម្លើយចំពោះវិញ្ញាសាសរសេរ វាយតម្លៃសិស្ស**

១. របស់ដែលសំខាន់គឺ ៖ ភាពស្មោះត្រង់ អ្នករាល់គ្នាគួរតែចូលរួម ត្រូវតែជឿជាក់គ្នាទៅវិញទៅមកទំនាក់ទំនងច្បាស់ ការយល់ព្រមជាសាធារណៈ បែងចែកការងារ បង្កើតនូវតារាងវេលា ធ្វើការត្រួតពិនិត្យឱ្យបានទៀងទាត់។

សិស្សត្រូវបង្ហាញរបស់ទាំងអស់នោះយ៉ាងហោចណាស់ឱ្យបានបី។

ត្រូវ៣ = ២ពិន្ទុ

ត្រូវ១ ឬ២ = ១ពិន្ទុ

២. គ្រប់ៗគ្នាត្រូវតែ*ដឹង និងយល់ព្រម*នៅពេលដែលអ្នកត្រូវបញ្ចប់កិច្ចការរបស់អ្នក។ មធ្យោបាយនេះ អ្នកទាំងអស់គ្នាអាចត្រួតពិនិត្យមើលគម្រោង*រួចរាល់ទាន់ពេលវេលា*។ ដោយមានការងារជាច្រើន អ្នកត្រូវមាន*សេចក្ដីសង្ខេបងាយស្រួល* ដូច្នេះអ្នកនឹងមិនអាចបំភ្លេចបាននូវកិច្ចការទាំងនោះ ហើយនឹងពេលវេលាដែលការងារទាំងអស់នោះត្រូវបានបញ្ចប់។ អ្នកត្រូវ*ធ្វើការប៉ាន់ប្រមាណនូវរយៈពេលដែលកិច្ចការនោះត្រូវការ។* នេះគឺពិតជាសំខាន់ណាស់ក្នុងការពិនិត្យមើលនូវចំនួនមនុស្សប៉ុន្មានអ្នកដែលអ្នកត្រូវការសម្រាប់ការងារនេះ។ ការងារកាន់តែធំ គឺត្រូវការមនុស្ស កាន់តែច្រើន។

ប្រសិនបើសិស្សបានឆ្លើយនូវចំណុចដែលបានសរសេររៀបរាប់ខាងលើយ៉ាងតិចណាស់២ ដូច្នេះពួកគេគឺបានឆ្លើយនូវចម្លើយត្រឹមត្រូវហើយ។

ត្រូវ២ = ២ពិន្ទុ

ត្រូវ១ = ១ពិន្ទុ

៣. ប្រសិនបើអ្នកគ្រាន់តែផ្ដល់យោបល់ មនុស្សទាំងអស់គ្នានឹងមានអារម្មណ៍ក្រៀមក្រំ ហើយក៏មិនមែនជាផ្នែកមួយនៃក្រុមផងដែរ។ វា គឺពិតជាសំខាន់ណាស់ដែលមនុស្សគ្រប់ៗគ្នាទទួលបាននូវការសរសើរ ចំពោះការសម្រេចបាននូវស្នាដៃដ៏តូចណាមួយផងដែរ។ ចំពោះមនុស្សដែលសប្បាយរីករាយ គឺតែងតែធ្វើការបានល្អនៅក្នុងក្រុម ហើយក៏ទៅកាន់ក្រុមផ្សេងទៀតក៏មានអារម្មណ៍វិជ្ជមានផងដែរ។

ត្រូវ = ១ពិន្ទុ

៤. សិទ្ធិកុមារ គឺជាសិទ្ធិដែលកុមារគ្រប់ៗគ្នានៅលើសកលលោកគួរតែទទួលបាន។ នេះគឺជាកិច្ចព្រមព្រៀងមួយដែល ត្រូវបានធ្វើឡើង ស្ទើរគ្រប់ប្រទេសទាំងអស់នៅលើពិភពលោក រួមបញ្ចូលប្រទេសកម្ពុជាផងដែរតាមរយៈអង្គការសហប្រជាជាតិ។ សិទ្ធិទាំងអស់អាចត្រូវបានស្វែងរកឃើញនៅលើផ្ទាំងរូបភាពធំៗ។

សិស្សត្រូវផ្ដល់នូវសិទ្ធិទាំងនោះយ៉ាងហោចណាស់ឱ្យបានមួយ។

ត្រូវទៅលើការពន្យល់អំពីសិទ្ធិកុមារ = ១ពិន្ទុ

ត្រូវយ៉ាងហោចណាស់សិទ្ធិចំនួនបី = ១ពិន្ទុ

៥. ការលេង គឺវាសំខាន់ណាស់ដើម្បី *បន្ធូរអារម្មណ៍ បញ្ចេញនូវសកម្មភាព និងធ្វើឱ្យរូបរាងការរីកលូតលាស់ អនុវត្តនូវអាកប្បកិរិយាសង្គម/សិក្សាអំពីការធ្វើការងារជាមួយគ្នា រកឃើញនូវចំណុចដែល អ្នកពូកែរៀនអំពីអាកប្បកិរិយារបស់អ្នកដទៃ គស៊ូយកឈ្នះ និងជំនះភាពចាញ់ មានភាពសប្បាយ រីករាយ។*

ត្រូវ២ ឬច្រើនជាង = ១ពិន្ទុ

៦. នេះមិនមែនជាការពិតទេ។ គ្រប់ៗគ្នា គឺសុទ្ធតែសំខាន់ ឱ្យតែយើងធ្វើការជាមួយគ្នា។ អ្នកដឹកនាំល្អម្នាក់ត្រូវ
ដឹងអំពីបញ្ហានេះ។

ត្រូវដោយមានការពន្យល់ = ២ពិន្ទុ

ត្រូវដោយមិនមានការពន្យល់ = ១ពិន្ទុ

៧. សំណួរ គឺត្រូវបានឆ្លើយត្រឹមត្រូវ ប្រសិនបើសិស្សបង្កើតតារាងមួយដែលមើលទៅ អាចមានលក្ខណៈស្រដៀងគ្នា នឹងតារាងខាងក្រោម ៖

| វិជ្ជមាន/ល្អ | អវិជ្ជមាន/មិនល្អ |
|---|---|
| | |
| | |

នឹងត្រូវបានសរសេរចូលយ៉ាងហោចណាស់ លទ្ធផលអវិជ្ជមានចំនួន២ និងវិជ្ជមានចំនួន២តារាងរួមបញ្ចូលមាន លទ្ធផលជាវិជ្ជមាន និងអវិជ្ជមានយ៉ាងហោចណាស់ចំនួន២ = ២ពិន្ទុ

មានត្រឹមតែតារាង និងលទ្ធផលវិជ្ជមាន/អវិជ្ជមានមួយ = ១ពិន្ទុ

៨. អាស្រ័យលើគំនិតរបស់គ្រូ។ ប្រសិនបើសិស្សពន្យល់បានល្អ ចម្លើយគឺត្រូវ។

ពន្យល់បានល្អ = ១ពិន្ទុ

៩. សៀវភៅកត់ត្រាលុយ គឺជាសៀវភៅដែលអ្នកអាចធ្វើការតាមដានមើលនូវចំណូល និង ចំណាយរបស់អ្នក។

ឆ្លើយបានល្អ = ១ពិន្ទុ

១០. អាស្រ័យលើគំនិតរបស់គ្រូ។ ប្រសិនបើការពន្យល់បានល្អ ដូច្នេះចម្លើយគឺត្រឹមត្រូវ។

ពន្យល់បានល្អ = ១ពិន្ទុ

កម្រិតនៃការផ្តល់ពិន្ទុ-ពិន្ទុនៅក្នុងការធ្វើតេស្តនេះ គឺទាក់ទងទៅនិងពិន្ទុទូទៅ

| %ឆ្លើយបានត្រឹមត្រូវ | ពិន្ទុ | និទ្ទេស |
|---|---|---|
| ៦៦%ទៅ១០០% ល្អ | ច្រើនជាង៩ពិន្ទុ | ល្អ |
| ៥១%ទៅ៦៥% ល្អ | ៨ទៅ៩ពិន្ទុ | បង្គួរ |
| ក្រោម៥០% ល្អ | តិចជាង ៨ពិន្ទុ | ខ្សោយ |

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ......................... សាលា....................... . ខេត្ត............... ស្រុក.................. ថ្នាក់ទី ........ ប្រធានបទ................

| ចំណុចត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | | |
| **សង្កេតឥរិយាបថសិស្ស** | | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្តាប់គ្នាទៅវិញទៅមក និងផ្តល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥០=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបខ្វាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត .......................... ស្រុក ........................សាលា ............................... ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | តំរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព　　　　　　　　　　ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា　　　　　　　　　　ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| **ការអង្កេតថ្នាក់រៀន** | **ការវាយតម្លៃគ្រូបំណិនជីវិត** |
|---|---|

| សាលារៀន | គ្រូ | អ្នកសង្កេត |
|---|---|---|
| | | |

| កាលបរិច្ឆេទ | ការចាប់ផ្ដើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិត: |
|---|---|---|---|---|---|
| | | | | | |

| តើមេរៀនបង្ហាញពីអ្វី? |
|---|
| |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្ដាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ? | 1-2-3-4-5 | |
| ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀនដោយមានតួនាទីក្រុមច្បាស់លាស់ | 1-2-3-4-5 | |
| រីករាយជាមួយមេរៀនដែលគ្រូបង្រៀន | 1-2-3-4-5 | |
| បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ? | 1-2-3-4-5 | *សូមបញ្ជាក់ធាតុណាមួយដែលត្រូវបានប្រើ* |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង? | 1-2-3-4-5 | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្ភាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ ......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ ....................................

ក្រសួងកិច្ចការនារី

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by giz

aecid